ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

# BUDGETING PROCESS OF PTC COMPUTER CO., LTD

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការរៀបចំគម្រោងថវិការបស់ ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

## BUDGETING PROCESS OF PTC COMPUTER CO., LTD

គ្រូណែនាំ៖ សុខ ផានឿន

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

## គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២
## ប្រធានបទ៖ ដំណើរការនៃការរៀបចំគម្រោងថវិការបស់
## ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សុខ ផានឿន

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថា ជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់សម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញ សំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ និងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្ត ការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជា អនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យ បានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេល នៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ បានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រង ក្នុងគោលបំណងឱ្យ អ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាព នៃដំណើរការនៃការរៀបចំគម្រោងថវិកា។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែក ក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សា ស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអាន ទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយ នឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**ហេង ណារី**
ID: B22/090



**សេង សុវណ្ណសក្តិ**
ID: B22/552



**សឿង ណៃគីម**
ID: B22/093



**ស៊ីម ចន្ធី**
ID: SP22/478



**រិន ស្រីនិច**
ID: B22/1823

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណដែលបានផ្តល់កំណើតដល់យើងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានព្យាយាមបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យធិការនៃសកលវទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះ លោកគ្រូ **សុខ ធារឿន** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិក នៃសកលវទ្យាល័យ វ៉ាន់ដា ទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនះ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "ដំណើរការនៃការរៀបចំគម្រោងថវិកា របស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី" នេះគឺជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹង របាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**




ហេង ណារី

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី (PTC Computer Co., LTD) បានបង្កើតឡើងនៅរាជធានីភ្នំពេញ នៅឆ្នាំ១៩៩៦ ដោយចាប់ផ្តើមជាអាជីវកម្មខ្នាតតូច ដែលជាក្រុមហ៊ុនលក្ខណៈគ្រួសារ រហូតក្លាយជាក្រុមហ៊ុនស្តង់ដា ដោយមានភាគហ៊ុន១០០ភាគរយពីម្ចាស់ក្រុមហ៊ុន គឺលោកអគ្គនាយក អ៊ឹង សែ ដែលមានសញ្ជាតិខ្មែរ។ ជាលទ្ធផលដែលក្រុមហ៊ុនបានខិតខំព្យាយាមតាំងពីដើមរហូតដល់បច្ចុប្បន្ននេះ យើងក៏នៅតែខិតខំប្រឹងប្រែងបន្តទៀត ដើម្បីសម្រេចបាននូវគោលដៅមួយនេះ។ ភាពស្មោះត្រង់ ភាពជឿជាក់ ក៏ដូចជាតម្លៃសមរម្យ និងសេវាកម្មដ៏ល្អផងដែរ ហើយរួមទាំងជំនាញបច្ចេកទេសដ៏ល្អបំផុតមួយនៅប្រទេសកម្ពុជា។

កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ក្នុងរយៈពេលទសវត្សកន្លងមកនេះបានផុតទៅយ៉ាងល្អប្រសើរដែលបាននាំឱ្យក្រុមហ៊ុនឈានទៅរកភាពរីកចម្រើន ជាក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានធំបំផុតក្នុងការផ្គត់ផ្គង់ផលិតផលពិតប្រាកដ និងសេវាកម្មដល់អតិថិជន។ ក្រុមហ៊ុនមានកិត្តិយសក្នុងការសហការធ្វើដៃគូជាមួយក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានអន្តរជាតិល្បីៗ ដែលជាអ្នកចែកចាយ និងអ្នកផ្គត់ផ្គង់សេវានៅកម្ពុជា។ ហើយក្រុមហ៊ុនក៏មានឯកទេសក្នុងការផ្គត់ផ្គង់ និងចែកចាយផលិតផលបច្ចេកវិទ្យា និងសម្ភារៈបច្ចេកវិទ្យាផ្សេងៗទៀត ព្រមទាំងមានសេវាកម្មជួសជុល ថែទាំ និងគាំទ្រផលិតផលដែលមានគុណភាពខ្ពស់ផងដែរ។ ក្នុងការជួសជុល ថែទាំង និងគាំទ្រផលិតផល ក្រុមហ៊ុនគឺមានបុគ្គលិកដែលមានបទពិសោធន៍ជាច្រើនឆ្នាំ ចំណេះជំនាញពិតជាមានវិជ្ជាជីវៈ មានវិញ្ញាបនបត្រត្រឹមត្រូវដែលអាចដឹងពីបញ្ហា និងដោះស្រាយពីបញ្ហាទាំងនោះដោយងាយស្រួល ទើបធ្វើឱ្យអតិថិជនទូទាំងប្រទេសរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី មានភាពជឿជាក់ក្នុងជ្រើសរើសយកមកប្រើប្រាស់រហូតមកដល់សព្វថ្ងៃនេះ។ បន្ថែមពីនេះទៀតប្រភពចំណាយរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី មានការសហការគ្រប់ផ្នែក ខាងក្រោមនេះយើងនឹង និយាយពីចំណាយតាមដំណាក់កាលនីមួយៗ ចំណាយធំរបស់ក្រុមហ៊ុន៖ គឺចំណាយលើការទិញផលិតផលគ្រឿងបច្ចេកវិទ្យាអេឡិចត្រូនិកមកលក់។ ការចំណាយថេររបស់ក្រុមហ៊ុន៖ ចំណាយលើប្រាក់ខែបុគ្គលិក ចំណាយជួលទីតាំង ចំណាយទិញសាំងសម្រាប់ចាក់គ្រឿងយន្តប្រើប្រាស់ ចំណាយទឹក ចំណាយភ្លើង ចំណាយលើទូរគមនាគមន៍ ចំណាយលើការទិញកាតទូរស័ព្ទ ចំណាយលើការទិញអាហារសម្រាប់បុគ្គលិក។ ចំណាយលើអ៊ីនធើណេត និងចំណាយតិចតួចមិនថេរ៖ ចំណាយលើសម្ភារៈការិយាល័យ ចំណាយលើការគ្រប់គ្រងសម្ភារៈដែលចំណាយលើការចុះបេសកកម្មផងដែរ។

សរុបរួមមកក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ពិតជាមានប្រតិបត្តិការទៅលើការគ្រប់គ្រងគម្រោងថវិកាបានយ៉ាងល្អ ដោយបុគ្គលិកគ្រប់ផ្នែកពោរពេញទៅដោយសមត្ថភាព ចំណេះដឹង ជំនាញ ក្រមសីលធម៌វិជ្ជាជីវៈ និងបទពិសោធន៍ការងារលើការអនុវត្តន៍តួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយទំនុកចិត្តខ្ពស់។ ហេតុនេះហើយទើបក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ទទួលបានការរីកចម្រើន និងភាពជឿជាក់ពីសំណាក់អតិថិជនរបស់ខ្លួនទាំងក្នុង និងក្រៅប្រទេសថែមទៀតផង។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១ តើក្រុមហ៊ុន ភីជីស៊ី កុំព្យូទ័រមានយុទ្ធសាស្រ្តក្នុងការរៀបចំគម្រោងថវិកាដូចម្តេច ?
២ តើការរៀបចំគម្រោងថវិការបស់ ក្រុមហ៊ុន ភីជីស៊ី កុំព្យូទ័រ មានផលប៉ះពាល់អ្វីខ្លះដល់អ្នករៀបចំ និងអង្គភាព ?
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ៣
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣
១.៥.១ ការប្រមូលទិន្នន័យដំបូង ........ ៣
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ........ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី២
## ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន

២.១ លក្ខណៈទូទៅនៃការរៀបចំគម្រោងថវិកា ........ ៦
២.១.១ និយមន័យគម្រោងថវិកា ........ ៦
២.១.២ ប្រភេទថវិកា ........ ៧
២.១.៣ និយមន័យនិងប្រវត្តិនៃការរៀបចំគម្រោងថវិកា ........ ៧
២.២ យុទ្ធសាស្រ្តក្នុងការរៀបចំគម្រោងថវិកា ........ ៨

២.២.១ និយមន័យយុទ្ធសាស្ត្រ ..........................................................................៨
២.២.២ ប្រវត្តិយុទ្ធសាស្ត្រ ..........................................................................៩
២.២.៣ យុទ្ធសាស្ត្រក្នុងការរៀបចំគម្រោងថវិកា ..........................................................................១០
២.៣ ផលប៉ះពាល់នៃដំណើរការថវិកា ..........................................................................១០
២.៣.១ និយមន័យផលប៉ះពាល់ ..........................................................................១០
២.៣.២ ផលប៉ះពាល់នៃដំណើរការថវិកា ..........................................................................១១

## ជំពូកទី៣
## ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ..........................................................................១៤
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ..........................................................................១៤
៣.១.២ ប្រវត្តិនិមិត្តសញ្ញាក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ..........................................................................១៥
៣.១.៣ អំពីក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ..........................................................................១៦
៣.២ យុទ្ធសាស្ត្រការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ..........................................................................២០
៣.២.១ ភាពចាំបាច់នៃការរៀបចំគម្រោងចំណាយរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី .២០
៣.២.២ ការរៀបចំគម្រោងចំណាយរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ..........................................................................២២
៣.២.៣ ប្រភពចំណាយ និងការត្រួតពិនិត្យចំណូលចំណាយរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី ..........................................................................២៣
៣.៣ ផលប៉ះពាល់នៃការគ្មានគម្រោងថវិកា ..........................................................................២៤

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ..........................................................................២៦
៤.២ ការវិភាគលើចំណុចខ្សោយ ..........................................................................២៧

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ..........................................................................២៨
៥.២ ការផ្តល់អនុសាសន៍ ..........................................................................២៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ឆ្លោះទៅតាមការសង្កេតឃើញតាមរយៈបណ្តាញសង្គម ឬបណ្តាញសារព័ត៌មានផ្សេងៗនៅលើពិភពលោកនេះមិនថាប្រទេសកំពុងអភិវឌ្ឍក្តី ប្រទេសអភិវឌ្ឍក្តីធ្វើឱ្យយើងឃើញថា ស្ថានភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះហាក់មានការរីកចម្រើនជាបន្តបន្ទាប់ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ទេសចរណ៍ វិស័យហិរញ្ញវត្ថុ និងធនាគារ ហើយជាពិសេសនោះគឺ វិស័យពាណិជ្ជកម្ម។ ដោយហេតុនេះមានន័យថា វិស័យពាណិជ្ជកម្ម គឺជាវិស័យមួយដែលគ្រប់បណ្តាលប្រទេសនានានៅលើពិភពលោកទាំងមូលមិនអាចខ្វះបាន ព្រោះថា ជាវិស័យមួយដែលបានចូលរួមជួយសម្រួលបន្ទុកជាច្រើនដល់សង្គមជាតិទាំងមូលក្នុងការផ្តល់ ឱកាសការងារដល់ប្រជាជន ផ្តល់ប្រាក់កម្រៃជូនប្រទេសជាតិ ក៏ដូចជាធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍថែមទៀតផង។ ទន្ទឹមនឹងការរីកចម្រើននេះផងដែរ យើងមើលឃើញនូវឱកាសការងារយ៉ាងសម្បូរសប្បាយ និងភាពងាយស្រួលកាន់តែប្រសើរឡើងរបស់ប្រជាជននៅក្នុងការប្រកបរបរការងារអាជីវកម្មជាច្រើននៅស្ទើរគ្រប់វិស័យ។

ក្នុងអំឡុងពេលដែលវិស័យក្រុមហ៊ុនពាណិជ្ជកម្ម នៅលើបណ្តាលប្រទេសកំពុងមានការរីកចម្រើន យើងក៏បានឃើញមានក្រុមហ៊ុនពាណិជ្ជកម្ម ជាច្រើនដែលបានជួយសម្រួលដល់ផ្នែកពាណិជកម្ម និងការដាក់វិនិយោគទុននានា ដោយហេតុថា នៅក្នុងនោះក៏យើងបានឃើញមាន **ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី** ដែលជាក្រុមហ៊ុនទូលំទូលាយមួយនៅប្រទេសកម្ពុជា។ ដោយសារការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី នេះយើងខ្ញុំក៏បានសង្កេតឃើញពីដំណើរការនានា នៃការរៀបចំសាច់ប្រាក់របស់ក្រុមហ៊ុនពាណិជ្ជកម្មនេះ។ ដូចដែលបានដឹងហើយថា ការរៀបចំរបាយការណ៍វាពិតជាមានសារៈសំខាន់ណាស់ ដើម្បីចាត់ចែងតម្រូវការរបស់អង្គភាពនានា។ ដើម្បីឱ្យយើងដឹង និងមើលឃើញពីតុល្យភាពរវាងចំណាយ ចំណូល ចំណេញខាតរបស់ក្រុមហ៊ុន ឬក៏អង្គភាពនីមួយៗ និងត្រូវមាននិតិវិធីច្បាស់លាស់ដើម្បីកំណត់គោលនយោបាយចំណូល ចំណាយប្រចាំខែ ប្រចាំឆ្នាំ និងការរៀបចំគម្រោងការចំណាយឱ្យបានត្រឹមត្រូវដោយជៀសវាងនូវការចំណាយណាមួយដែលមិនចាំបាច់ដែលនាំឱ្យមានចំណាយកើនឡើងដោយគ្មានមូលហេតុនឹងនាំឱ្យក្រុមហ៊ុនបាត់បង់ប្រាក់ចំណេញផ្សេងៗ។ បន្ថែមពីនេះ ការរៀបចំផែនការចំណាយយ៉ាងម៉ត់ចត់អាចជួយក្រុមហ៊ុនក្នុងការជៀសវាងចំណាយដែលមិនចាំបាច់ដែលអាចនាំឱ្យកើនប៉ុនប៉ងចំណាយដោយគ្មានមូលហេតុច្បាស់ ហើយជាធម្មតាអាចបណ្តាលឱ្យក្រុមហ៊ុនបាត់បង់ប្រាក់ចំណេញ។ ដូច្នេះ ការគ្រប់គ្រងសាច់ប្រាក់ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុយ៉ាងត្រឹមត្រូវ គឺជាចំណុចមួយសំខាន់សម្រាប់ភាពជោគជ័យរបស់ក្រុមហ៊ុនពាណិជ្ជកម្ម។

ដើម្បីឱ្យកាន់តែក្បោះក្បាយ និងស្វែងយល់ឱ្យកាន់តែលម្អិតជាងនេះអំពីដំណើរការនៃការរៀបចំថវិកា និងអត្ថប្រយោជន៍របស់ក្រុមហ៊ុនពាណិជ្ជកម្ម។ ក្រុមយើងខ្ញុំក៏បានលើកឡើងមកនូវប្រធានបទមួយគឺ " **ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កំព្យូទ័ ខូ អិលធីឌី** " យកមកសិក្សាស្រាវជ្រាវ

បន្ថែម និងធ្វើការចងក្រងបោះពុម្ពទុកសម្រាប់ជាគុណប្រយោជន៍ដល់សិស្សានុសិស្សជំនាន់ក្រោយយកមកទុកជាឯកសារមេរៀនសម្រាប់សិក្សាស្រាវជ្រាវផ្សេងៗ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្ថាប័នមួយ ឬក្រុមហ៊ុនពាណិជ្ជកម្មមួយមានការរីកចម្រើនបានលុះត្រាណាតែក្រុមហ៊ុននោះមានដំណើរការនៃការរៀបចំថវិកាមួយដែលមានភាពរឹងមាំច្បាស់លាស់ល្អប្រសើរ ទើបធ្វើឱ្យដំណើរការនៃការធ្វើអាជីវកម្មមួយនោះទទួលបានជោគជ័យ ហើយជាពិសេសនោះ គឺការចេះរៀបចំ និងគ្រប់គ្រងថវិកា។ ជាពិសេសគឺ ភាពចេះដឹងនៅក្នុងការគ្រប់គ្រងថវិកា គឺជាផ្នែកមួយដ៏សំខាន់បំផុតសម្រាប់ក្រុមហ៊ុន ឬស្ថាប័នក្នុងការចាយវាយ ឬការទូទាត់ប្រាក់ចំណាយផ្សេងៗនៅក្នុងក្រុមហ៊ុន។ ដោយការសហការក្នុងការគ្រប់គ្រងថវិកាមានសារៈសំខាន់ដូច្នេះ ទើបក្រុមរបស់យើងខ្ញុំបានធ្វើការសម្រេចចិត្តជ្រើសរើសប្រធានបទមួយលើកឡើងថា "ដំណើរកានៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី"។

**១.តើក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រមានយុទ្ធសាស្ត្រក្នុងការរៀបចំគម្រោងថវិកាដូចម្តេច?**

**២.តើការរៀបចំគម្រោងថវិការបស់ ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ មានផលប៉ះពាល់អ្វីខ្លះដល់អ្នករៀបចំ និងអង្គភាព?**

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវអំពី "**ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ**" មានគោលបំណងសំខាន់ៗដូចតទៅៈ

- សិក្សាពីគោលនយោបាយ និងវិធីសាស្ត្រដែលក្រុមហ៊ុនបានអនុវត្តសម្រាប់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងប្រចាំខែ។
- វិភាគស្ថានភាពទូទៅ និងដំណើរការសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ដើម្បីយល់អំពីបរិបទសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។
- ពិភាក្សាអំពីដំណើរការរៀបចំគម្រោងថវិកា ដូចជា ដំណាក់កាល បច្ចេកទេស និងឯកសារសំខាន់ៗដែលពាក់ព័ន្ធ។
- វិភាគផលវិបាកនៃការមានបញ្ហា ឬការខ្វះខាតនៃគម្រោងថវិកាដែលអាចមានផលប៉ះពាល់ដល់ប្រសិទ្ធភាពអាជីវកម្ម។
- បញ្ជាក់ពីតួនាទី និងសារៈសំខាន់របស់ការរៀបចំគម្រោងថវិកាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព។
- បង្ហាញពីសារៈសំខាន់នៃគម្រោងថវិកាជាឧបករណ៍គ្រប់គ្រងធនធានផ្ទៃក្នុងដែលអាចជួយឱ្យអង្គភាពអាចសម្រេចបាននូវគោលដៅសេដ្ឋកិច្ច និងការអភិវឌ្ឍន៍យ៉ាងច្បាស់លាស់។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសិក្សាស្រាវជ្រាវនេះ បានផ្តោតសំខាន់ទៅលើបញ្ហា និងដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ។ ដែលមានទីតាំងស្ថិតនៅលើមហាវិថីព្រះមុន្នីវង្ស អគារលេខ ២៥០ និង ២៥២ រាជធានីភ្នំពេញ។ ការស្រាវជ្រាវនេះមានបំណងស្វែងយល់ពីរបៀបដែលក្រុមហ៊ុន

រៀបចំ និងគ្រប់គ្រងថវិកា ដូចជាផ្នែកគោលនយោបាយ វិធីសាស្ត្រ បញ្ហាប្រឈម និងសារៈសំខាន់នៃការមានគម្រោងថវិកាដែលមានប្រសិទ្ធភាព សម្រាប់ជាឧបករណ៍គ្រប់គ្រងធនធានផ្ទៃក្នុង។"

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ក្នុងបរិបទនៃការសិក្សាស្រាវជ្រាវនេះ ក្រុមស្រាវជ្រាវបានកំណត់វិសាលភាពសម្រាប់យកឯកសារគណនេយ្យ និងឯកសារដែលពាក់ព័ន្ធនឹងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ **២០២៤** និង **២០២៥** របស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ដើម្បីយកមកធ្វើជាគំរូសិក្សា និងវិភាគ។ ការសិក្សានេះក៏រួមបញ្ចូលនូវការចុះកម្មសិក្សា នៅទីស្តីការកណ្តាលរបស់ក្រុមហ៊ុន ដើម្បីប្រមូលព័ត៌មានបន្ថែមតាមផ្ទាល់ និងសម្រេចបាននូវទិន្នន័យដ៏មានតម្លៃសម្រាប់ការវិភាគដល់ដំណើរការនៃការរៀបចំគម្រោងថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យការសរសេរសារណាទៅលើប្រធានបទដែលស្តីអំពី "ដំណើរការនៃការរៀបចំគម្រោងថវិកា របស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ " ឱ្យបានជោគជ័យក្រុមនាងខ្ញុំធ្វើការស្រាវជ្រាវតាមវិធីសាស្ត្រ **"បែបគុណវិស័យ"**។ ដែលវិធីសាស្ត្រនេះ ពួកយើងធ្វើការដកស្រង់ទិន្នន័យពីគេហទំព័រផ្សេងៗក៏ដូចជាឯកសារដែលពាក់ព័ន្ធដើម្បីបកស្រាយនៅចំណោទបញ្ហារបស់ដំណើរការ នៃការរៀបចំគម្រោងនេះ។

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ការប្រមូលទិន្នន័យដំបូងជាជំហានសំខាន់មួយនៅក្នុង ដំណើរការស្រាវជ្រាវផ្សេងៗ ដែលមានគោលបំណងដើម្បីទទួលបានព័ត៌មានថ្មីៗផ្ទាល់ពីប្រភពដើម។ មួយវិញទៀត ទិន្នន័យដំបូងគឺជាទិន្នន័យដែលអ្នកស្រាវជ្រាវបានប្រមូលផ្ទាល់ដោយប្រើវិធីសាស្ត្រផ្សេងៗដូចជា៖ ការសម្ភាសន៍ (Interview), ការស្ទង់មតិ (Survey/Questionnaire), ការសង្កេតការណ៍ (Observation), និងការពិគ្រោះយោបល់ជាមួយអ្នកជំនាញ (Focus Group Discussion)។

### ១.៥.២ ការប្រមូលទិន្នន័យបន្ទាប់

ការប្រមូលទិន្នន័យបន្ទាប់ជាដំណាក់កាលមួយនៃដំណើរការស្រាវជ្រាវ ដែលអនុញ្ញាតឱ្យអ្នកស្រាវជ្រាវទទួលបានព័ត៌មានពីប្រភពដែលមានស្រាប់។ ទិន្នន័យបន្ទាប់នេះអាចមានដូចជា៖ របាយការណ៍ផ្លូវការ សៀវភៅ ការសិក្សាផ្សេងៗដែលបានផ្សាយចេញពីស្ថាប័ន ជាសារព័ត៌មាន ឬជាអត្ថបទស្រាវជ្រាវ មូលដ្ឋានទិន្នន័យអេឡិចត្រូនិក និងឯកសារផ្លូវការផ្សេងៗ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពីក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវលើប្រធានបទនេះបានធ្វើឱ្យក្រុមយើងខ្ញុំយល់ដឹងពីសារៈសំខាន់ពីដំណើរការនៃការរៀបចំគម្រោងថវិកាដូចជា៖

**១. សម្រាប់អ្នកស្រាវជ្រាវ**

- ការស្រាវជ្រាវជួយឱ្យអ្នកស្រាវជ្រាវយល់ដឹងច្បាស់អំពីតម្រូវការផ្នែកហិរញ្ញវត្ថុ
- ជួយកំណត់អាទិភាពក្នុងការចំណាយ
- ជួយរៀបចំគម្រោងថវិកាដោយមានប្រសិទ្ធភាព
- បង្ហាញភាពជាក់លាក់ នៃគម្រោងស្រាវជ្រាវ

- ជានាថាគម្រោងអាចអនុវត្តបានក្នុងភាពជាក់ស្តែង។

**២. សម្រាប់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ**

- ជួយឱ្យក្រុមហ៊ុនមានយុទ្ធសាស្ត្រថវិកាដែលមានប្រសិទ្ធភាពសម្រាប់គម្រោងផ្សេងៗ
- ជួយព្យាករណ៍ចំណាយ និងប្រាក់ចំណូលក្នុងអនាគតបានត្រឹមត្រូវ
- គ្រប់គ្រងធនធានហិរញ្ញវត្ថុបានប្រសើរឡើង
- កាត់បន្ថយការបាត់បង់ធនធានដោយសារតែការរៀបចំថវិកាមិនល្អ។

**៣. សម្រាប់សង្គមជាតិ**

- ការស្រាវជ្រាវគម្រោងថវិកាមានសារៈសំខាន់ក្នុងការធានាប្រសិទ្ធភាព នៃការប្រើប្រាស់ធនធានជាសាធារណៈ។
- ជួយឱ្យមានការបែងចែកធនធានយ៉ាងសមរម្យទៅតាមតម្រូវការផ្សេងៗ
- គាំទ្រការអភិវឌ្ឍសង្គមនៅគ្រប់វិស័យ ដូចជា៖ សុខាភិបាល អប់រំ និងបច្ចេកវិទ្យាដើម្បីបង្កើនគុណភាពជីវិត និងសមភាពសង្គមសម្រាប់ប្រជាជនទូទៅ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធ នៃការស្រាវជ្រាវរបស់ក្រុមហ៊ុន **ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី** មានដូចខាងក្រោម៖

- **ជំពូកទី១៖ សេចក្តីផ្តើម**

ក្នុងជំពូកទី១ គឺជាការចាប់ផ្តើមដំបូងដែលទាក់ទងនឹងចំណុចសំខាន់ទាំង ៧រួមមានដូចជា៖ លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ទំហំដែនកំណត់ និងវិសាលភាព វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់ នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធ នៃការស្រាវជ្រាវ។

- **ជំពូកទី២៖ ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន**

ក្នុងជំពូកទី២ គឺសិក្សាពីដំណើរការនៃការរៀបចំគម្រោងថវិកាដែលបានដកស្រង់ចេញពីសៀវភៅ និងសារណាបញ្ចប់របស់សិស្សច្បង និងទិន្នន័យផ្ទាល់របស់ក្រុមហ៊ុន រួមទាំងគេហទំព័រអ៊ីនធឺណេតផ្សេងៗដែលមានដូចខាងក្រោម៖

  - លក្ខណៈទូទៅ នៃការរៀបចំគម្រោងថវិកា
  - និយមន័យការរៀបចំគម្រោងថវិកា
  - យុទ្ធសាស្ត្រក្នុងការរៀបចំគម្រោងថវិកា
  - ប្រវត្តិយុទ្ធសាស្ត្រ
  - ផលប៉ះពាល់ នៃដំណើរការរៀបចំគម្រោងថវិកា។

- **ជំពូកទី៣៖ ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី**

ក្នុងជំពូកទី៣ គឺបកស្រាយ និងពន្យល់ពីស្ថានភាពទូទៅ និងដំណើរការរួមជាមួយនឹងនីតិវិធីផ្សេងៗ នៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ីកុំព្យូទ័រ ខូ អិលធីឌី។

- **ជំពូទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ**

ក្នុងជំពូកទី៤ គឺបកស្រាយបង្ហាញពីចំណុចដែលល្អប្រសើរ និងចំណុចដែលខ្វះខាត ដើម្បីចូលរួមក្នុងការរិះគន់ក្នុងគោលបំណងកែលម្អឱ្យល្អប្រសើរឡើងវិញ។

- **ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍**

ក្នុងជំពូកទី៥ គឺជាជំពូកចុងក្រោយដែលបង្ហាញពីការសរុបអត្ថន័យខាងលើ រួចសន្និដ្ឋាន និងផ្ដល់ជាមតិយោបល់ជូនក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន

## ២.១ លក្ខណៈទូទៅនៃការរៀបចំគម្រោងថវិកា

### ២.១.១ និយមន័យគម្រោងថវិកា

- **ថវិកា (Budget)** គឺជាចំនួនទឹកប្រាក់ដែលត្រូវការ ឬមានសម្រាប់គោលបំណងណាមួយ។
- **ថវិកា (Budget)** មានន័យថា ជាផែនការចំណាយ ចំណូល ដើម្បីធ្វើសមតុល្យការចំណាយ ដែលជាធម្មតាជាអាជ្ញាធរសាធារណៈ[1]។
- **ថវិកា** គឺជាការបញ្ចេញមតិហិរញ្ញវត្ថុ ដែលជាការរួមបញ្ចូលចំណូលនិង ចំណាយ[2]។
- **ថវិកា (Budget)** គឺជាការប៉ាន់ប្រមាណនៃប្រាក់ចំណូល និងការចំណាយក្នុងរយៈពេលជាក់លាក់ណាមួយនាពេលអនាគត ហើយត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលអាជីវកម្ម និងបុគ្គលនៅប្រាក់ចំណូលណាមួយ[3]។
- **ថវិកា (Budget)** ជាឯកសារដែលរៀបរាប់ពីការបែងចែកហិរញ្ញវត្ថុសម្រាប់សកម្មភាព ឬគោលដៅជាក់លាក់ក្នុងកំឡុងពេលណាមួយ ។
- **ថវិកា (Budget)** គឺជាផែនការចំណាយដោយផ្អែកលើចំណូល និងចំណាយ។ ម្យ៉ាងវិញទៀត វាជាការប៉ាន់ប្រមាណអំពីចំនួនប្រាក់ដែលអ្នកនឹងរកបាន និងចំណាយក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយដូចជា មួយខែ ឬមួយឆ្នាំ ។
- **ថវិកា (Budget)** គឺជាផែនការហិរញ្ញវត្ថុដែលបានបង្ហាញពីប្រាក់ចំណូល និងការចំណាយដែលរំពឹងទុកសម្រាប់រយៈពេលដែលបានកំណត់។ នៅក្នុងបរិបទធុរៈកិច្ចថវិកាអាចជាផែនកាថវិកាដែលបានបែងចែកធនធានដើម្បីសម្រេចបាននូវគោលបំណងរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព។
- **ថវិកា (Budget)** គឺជាផែនការដែលអនុម័តក្នុងការចំណាយប្រាក់ជាក់លាក់មួយនៅក្នុងឆ្នាំសារពើពន្ធ ឬរយៈពេលគ្រោងទុក[4]។

ដំណើរការរៀបចំគម្រោងថវិកាជាធម្មតារួមមានជំហ៊ានសំខាន់ៗដូចខាងក្រោម៖

- ការកំណត់គោលដៅ៖ ការកំណត់គោលដៅហិរញ្ញវត្ថុដែលថវិកានឹងជួយស្រេមចបាន។ នេះអាចរួមបញ្ចូលការសន្សំស្រមាប់ការទិញជាក់លាក់កាត់បន្ថយការចំណាយបង្កើនប្រាក់ចំណូល ឬការស្រេមចបាននូវក្រមិតជាក់លាក់ នៃប្រាក់ចំណេញ។
- ការប៉ាន់ប្រមាណប្រាក់ចំណូល៖ ការព្យាករណ៍ពីប្រាក់ចំណូលដែលរំពឹងទុកដូចជា ប្រាក់ខែ ប្រាក់ចំណូលពីការលក់ និងការវិនិយោគ ឬទម្រង់ចំណូលផ្សេងទៀត។

---

[1] Wiktionary. (2025, April 12). *ថវិកា.* Retrieved from https://km.wiktionary.org/wiki/ថវិកា

[2] Investopdia. *By Akhilesh Ganti.* (2025, June 21). *What Is a Budget? Plus 11 Budgeting Myths Holding You Back.* Retrieved from https://www.investopedia.com/terms/b/budget.asp

[3] ថវិកាជាតិកម្ពុជា. (2025, June 21). *ថវិកាជាតិគឺជាអ្វី?* Retrieved from https://www.cambodianbudget.org/index.php?page=00116&Language=2

[4] ASIA SOCIETY POLICY INSTITUTE. *ថវិការ.* Retrieved 2025, June 21 from https://asiasociety.org/policy-institute

ការប៉ាន់ប្រមាណប្រាក់ចំណាយ៖ ការគិតទុកជាមុន និងចាត់ថ្នាក់ការចំណាយថេរ។

- ការបង្កើនថវិកា៖ ចងក្រងចំណូល និងចំណាយដែលប៉ាន់ប្រមាណចូលក្នុងឯកសារថវិកាដ៏ទូលំទូលាយដែលបង្ហាញពីរបៀបដែលធនធានហិរញ្ញវត្ថុត្រូវបានបែងចែកក្នុងរយៈកំណត់ណាមួយដូចជា ខែ ត្រីមាស ឬឆ្នាំ។
- ការត្រួតពិនិត្យ៖ ការតាមដានប្រាក់ចំណូល និងចំណាយជាក់លាក់ធៀបនឹងថវិកា ដើម្បីកំណត់អត្តសញ្ញាណ ភាពខុសគ្នា ឬការប្រែប្រួលណាមួយ ដែលពាក់ពន្ធនឹងការត្រួតពិនិត្យ ការវិភាគជាប្រចាំនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីស្វែងយល់ពីតម្រូវការហិរញ្ញវត្ថុ។
- ការកែសម្រួលថវិកា៖ ធ្វើការកែសម្រួលថវិកាដោយផ្អែកលើការអនុវត្តហិរញ្ញវត្ថុជាក់ស្តែង និងការផ្លាស់ប្តូរតាមកាលៈទេសៈ។
- របាយការណ៍ និងការវិភាគ៖ ទំនាក់ទំនងការអនុវត្តលើថវិកាទៅកាន់ភាគីពាក់ព័ន្ធតាមរយៈរបាយការណ៍ និងបទបង្ហាញ។
- ការកែលម្អជាបន្តបន្ទាប់៖ ការប្រើប្រាស់ការយល់ដឹងដែលទទួលបានពីដំណើរនៃការរៀបចំគម្រោងថវិកា ដើម្បីកែលម្អថវិកានាពេលអនាគត និងផែនការហិរញ្ញវត្ថុរួម[5]។

**២.១.២ ប្រភេទថវិកា**

ប្រភេទ នៃថវិកាមានច្រើនប្រភេទដែលអាចបែងចែកទៅតាមគោលបំណង និងសកម្មភាពដូចជា៖

- ថវិកាជាលក្ខណៈប្រតិបត្តិការ (Operational Budget)៖ ថវិកាសម្រាប់សកម្មភាពប្រតិបត្តិការ និងការចំណាយប្រចាំថ្ងៃ។
- ថវិកាជាលក្ខណៈវិនិយោគ (Capital Budget)៖ ថវិកាសម្រាប់គម្រោងវិនិយោគធំៗ ឬការទិញទ្រព្យសម្បត្តិអចលនទ្រព្យ។
- ថវិកាជាលក្ខណៈការផ្សព្វផ្សាយ (Marketing Budget)៖ ថវិកាសម្រាប់សកម្មភាពផ្សព្វផ្សាយផលិតផលឬសេវាកម្ម ។

**២.១.៣ ប្រវត្តិគម្រោងថវិកា**

គម្រោងថវិកាមានប្រវត្តិជាយូរអង្វែងមកហើយ ដែលទាក់ទងនឹងការគ្រប់គ្រងធនធានក្នុងសង្គម និងការចំណាយក្នុងសេដ្ឋកិច្ចនានា។ ការធ្វើផែនការថវិកាបានកកើតឡើងអស់ជាច្រើនសតវត្សមកហើយ ដោយសម័យដើមទាំងនោះបានបែងចែកបានជាដំណាក់កាលសំខាន់ៗដូចខាងក្រោម៖

១. សម័យបុរាណ

- ប្រជាជនប្រើវិធីសាស្ត្រសាមញ្ញ ដើម្បីរៀបចំធនធានសម្រាប់ជីវភាពប្រចាំថ្ងៃ និងការប្រព្រឹត្តសកម្មភាពជាសាធារណៈ។

[5] AMD. (2025, June 15). *គម្រោងថវិកា.* Retrieved from https://economy.ams.com.kh/finance

- នៅប្រទេសចិនបុរាណ និងអេហ្ស៊ីបបុរាណ ការរាប់ចំនួនផលផលិត និងការរៀបចំសកម្មភាពធនធានសម្រាប់សេដ្ឋកិច្ចត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។

២. សម័យមជ្ឈមកាល

- ការគ្រប់គ្រងថវិកាបានចាប់ផ្តើមរីកចម្រើននៅក្នុងសម័យមជ្ឈមកាល ដោយការឆ្លៀតប្រើផែនការសម្រាប់ការចំណាយនៅក្នុងកិច្ចសង្គ្រាម និងសកម្មភាពសាសនា។
- នៅអឺរ៉ុបការគ្រប់គ្រងថវិកាត្រូវបានប្រើដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិង ការប្រើប្រាស់ធនធានសាសនាដោយមានការរៀបចំផែនការចំណាយចំណូលរបស់អង្គការកាតូលិកជាដើម។

៣. សតវត្សទី១៧ និងទី១៨

- ក្នុងសម័យនេះជាមួយនឹងការរីកចម្រើន នៃបដិវត្តន៍ឧស្សាហកម្ម នៅសតវត្សទី១៧ និងទី១៨ គម្រោងថវិកាបានក្លាយជាឧបករណ៍សំខាន់សម្រាប់អាជីវកម្ម និងការគ្រប់គ្រងសេដ្ឋកិច្ច។
- វិធីសាស្ត្រសម្រាប់ការគ្រប់គ្រងការចំណាយ និងការប្រមូលចំណូលត្រូវបានបង្កើនប្រសិទ្ធភាពដោយប្រើគំនិតសាមញ្ញក្នុងការបែងចែកធនធាន។

៤. សតវត្សទី២០ និងទី២១

- ក្នុងសតវត្សទី២០ការរៀបចំគម្រោងថវិកាបានរីកចម្រើនយ៉ាងឆាប់រហ័ស។ការចងសាជាមួយនឹងបច្ចេកវិទ្យាដែលរីកចម្រើនបានជួយឱ្យការរៀបចំគម្រោងថវិកាកាន់តែងាយស្រួល។
- Software និងប្រព័ន្ធគ្រប់គ្រងទំនើបត្រូវបានបង្កើតឡើង ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង។
- នៅសតវត្សទី២១ គម្រោងថវិកាក្លាយជាផ្នែកមួយសំខាន់សម្រាប់អាជីវកម្ម និងការគ្រប់គ្រងសេដ្ឋកិច្ចរបស់ប្រទេសផ្សេងៗ។

គម្រោងថវិកានៅសព្វថ្ងៃមានតួនាទីសំខាន់សម្រាប់ការគ្រប់គ្រងធនធាន ហើយវាបានក្លាយជាគន្លងដ៏សំខាន់សម្រាប់ការគ្រប់គ្រងអង្គការ និងសេដ្ឋកិច្ច[6]។

## ២.២ យុទ្ធសាស្ត្រក្នុងការរៀបចំគម្រោងថវិកា

### ២.២.១ និយមន័យយុទ្ធសាស្ត្រ

**យុទ្ធសាស្ត្រ (Strategy)** គឺជាផែនការយ៉ាងជាក់លាក់ ឬវិធីសាស្ត្រដែលត្រូវបានរៀបចំឡើងដើម្បីសម្រេចគោលបំណង ឬគោលនយោបាយជាក់លាក់មួយ។ វាជាគម្រោងរយៈពេលវែងដែលនាំឱ្យអង្គភាពអាចប្រើធនធាន និងសមត្ថភាពរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព ដើម្បីឈ្នះក្នុងការប្រកួតប្រជែង ឬសម្រេចបេសកកម្ម[7]។

[6] រៀបរៀងដោយនិស្សិតឈ្មោះ ស៊ីម ស្រីពេជ, អឿង ណារ៉ា, គុយ នាគ, អែម ស្រីឃីម. (២០២១). ប្រធានបទ៖ *ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន កូកា-កូឡា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២១ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៥។ ភ្នំពេញ។

[7] រៀបរៀងដោយនិស្សិតឈ្មោះ ស៊ីម ស្រីពេជ, អឿង ណារ៉ា, គុយ នាគ, អែម ស្រីឃីម. (២០២១). ប្រធានបទ៖ *ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន កូកា-កូឡា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២១ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៦។ ភ្នំពេញ។

**យុទ្ធសាស្ត្រ** ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងវិស័យ នយោបាយ យោធា សេដ្ឋកិច្ច និងជំនួញ។ យោបល់នឹងមតិ នៃពាក្យយុទ្ធសាស្ត្រមានច្រើនប្រភេទណាស់ដែលយើងអាចសិក្សាបាន ប្រសិនបើយើងក្រឡេកមើលទៅលើព្យញ្ជនៈនេះ គឺពិតជាមានសារៈសំខាន់ដល់បុគ្គល ស្ថាប័ន ឬម្ចាស់មុខជំនួញ ម្ចាស់ប្រតិបត្តិការនៅក្នុងក្រុមហ៊ុននេះមានបំណងចង់ធ្វើការនៅក្នុងអនាគត។

### ១. និយមន័យទូទៅ

**យុទ្ធសាស្ត្រ** គឺជាផែនការ ឬគំនិតវែងៗ ដែលត្រូវបានរៀបចំឡើងយ៉ាងប្រុងប្រយ័ត្ន ដើម្បីសម្រេចគោលដៅជាក់លាក់មួយ។ វាជាគន្លង ឬទិសដៅក្នុងការប្រព្រឹត្តសកម្មភាពសម្រាប់ឈានទៅរកភាពជោគជ័យ។

### ២. តាមមូលដ្ឋានអាជីវកម្ម

**យុទ្ធសាស្ត្រ** គឺជាការរៀបចំ និងប្រើប្រាស់ធនធានរបស់ស្ថាប័នយ៉ាងមានប្រសិទ្ធភាព ដើម្បីចូលរួមប្រកួតប្រជែង និងសម្រេចគោលដៅរយៈពេលវែង។ វាជាវិធីសាស្ត្រប្រយុទ្ធក្នុងទីផ្សារ។

### ៣. តាម Michael Porter (1980)

"Strategy means choosing to perform activities differently or to perform different activities than rivals do."

**យុទ្ធសាស្ត្រ** គឺជាចំណាំក្នុងការជ្រើសរើសសកម្មភាព ឬវិធីសាស្ត្រដែលខុសពីគូប្រកួត ដើម្បីទទួលបានអត្ថប្រយោជន៍ប្រកួតប្រជែង។

### ៤. តាម David (2009)

**យុទ្ធសាស្ត្រ** គឺជា "ការរៀបចំគោលនយោបាយ និងការអនុវត្តសកម្មភាព ដែលអាចធ្វើឱ្យស្ថាប័នឈានទៅរកគោលដៅវែង ដោយប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត"។

### ៥. តាមសិស្សសាលា/សាមញ្ញ៖

**យុទ្ធសាស្ត្រ** មានន័យថាគឺជា ផែនការធំសម្រាប់អង្គភាពដើម្បីឈានទៅរកភាពជោគជ័យ ដោយប្រើប្រាស់ធនធាន ខ្យល់គំនិត និងវិធីសាស្ត្រដែលបានរៀបចំជាប្រព័ន្ធ[8]។

### ២.២.២ ប្រវត្តិយុទ្ធសាស្ត្រ

ពាក្យនេះក្លាយមកពីពាក្យក្រិច **Strategos** ដែលមានន័យថា "មេទ័ព ឬ មេបញ្ជាការ កងទ័ព"។ ក្នុងភាសាខ្មែរ វាក្លាយមកពីពាក្យ "យុទ្ធសាស្ត្រ < យុទ្ធ + សាស្ត្រ"។ យុទ្ធ ជាពាក្យបាលីសំស្រ្កឹត មានន័យថា ចម្បាំង ឬសង្គ្រាម។ ចំណែកឯ សាស្ត្រ ជាពាក្យបាលីសំស្រ្កឹតដូចគ្នា និងមានន័យថា ក្បួន ឬគម្ពីរ។ សរុបមក យុទ្ធសាស្ត្រមានន័យថា ជាក្បួនចម្បាំង ឬក្បួនសម្រាប់ច្បាំង។

យុទ្ធសាស្ត្រត្រូវបានប្រើយ៉ាងទូលំទូលាយក្នុងវិស័យ នយោបាយ យោធា សេដ្ឋកិច្ច និងជំនួញ។ កន្លងមកមានអ្នកប្រាជ្ញ ជាច្រើនបានចងក្រងទ្រឹស្តី នៃយុទ្ធសាស្ត្រ ហើយខ្លះមានប្រវត្តិតាំងពីមុន

[8] KHsearch. គ្រប់គ្រង. (2020, June 15). *តើអ្វីទៅជាយុទ្ធសាស្ត្រ?* Retrieved from https://www.khsearch.com/qna/31418

គ្រឹះសករាជមកម្ល៉េះ។ ក្នុងចំណោមនោះមាន ដូចជាលោក ស៊ុន ស៊ូ (ស.វ ទី៦ មុន គ.ស) ចាណាក្យា (ស.វ ទី៤ មុន គ.ស) ម៉ៅសេទុង ម៉ែឃើល ផតធើរ ខាលវ៉ុន ក្លូសវីជ ជាដើម[9]។

### ២.២.៣ យុទ្ធសាស្ត្រក្នុងការរៀបចំគម្រោងថវិកា

យុទ្ធសាស្ត្រថវិកា គឺមានគោលបំណងផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យបាននៅការគ្រប់គ្រង និងប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ម្យ៉ាងទៀត ផែនការយុទ្ធសាស្ត្រថវិកាផ្តល់ជាមូលដ្ឋានដល់ការរៀបចំកម្មវិធី ហើយក៏ជាឧបករណ៍សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ទាំងថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍដែលជាគោលដៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ផែនការយុទ្ធសាស្ត្រថវិកា នឹងត្រូវធ្វើសមាហរណកម្មជាមួយក្របខណ្ឌចំណាយរយៈពេលមធ្យមសម្រាប់ជាឧបករណ៍ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងសម្រាប់ជាធាតុចូលដល់ការវិភាជន៍ថវិកាប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព ពីព្រោះក្របខណ្ឌចំណាយរយៈពេលមធ្យមត្រូវបានរៀបចំឡើងតាមអភិក្រមពីលើចុះក្រោមនៅក្នុងការកំណត់កញ្ចប់ថវិកាទៅតាមវិស័យដោយផ្អែកលើក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងអត្ថិភាពគោលនយោបាយរីឯផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំឡើងតាមអភិក្រឹត្យពីក្រោមឡើងលើដោយបង្ហាញឱ្យឃើញពីតម្រូវការថវិកាជាក់ស្តែងតាមក្រសួង-ស្ថាប័ន និងវិស័យនៅក្នុងការអនុវត្តគោលនយោបាយអាត្ថិភាពតាមវិស័យ[10]។

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងដោះស្រាយបញ្ហាសំខាន់៤ ដូចខាងក្រោម៖

- ស្ថានភាពបច្ចុប្បន្នរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្ត
- ការត្រួតពិនិត្យតាមដាន
- ចក្ខុវិស័យរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត
- មធ្យោបាយសម្រេចឱ្យបាននូវចក្ខុវិស័យដែលបានកំណត់ ។

## ២.៣ ផលប៉ះពាល់នៃដំណើរការនៃការរៀបចំថវិកា

### ២.៣.១ និយមន័យនៃផលប៉ះពាល់

**ផលប៉ះពាល់** គឺជាផលលទ្ធផល ឬអត្ថប្រយោជន៍ និងគ្រោះថ្នាក់ដែលអាចកើតមានចំពោះសកម្មភាព ឬដំណើរការណាមួយ។

**ផលប៉ះពាល់**នៃគម្រោងថវិកា គឺសំដៅទៅលើផលប៉ះពាល់ទាំងឡាយណាដែលអាចមានចំពោះក្រុមហ៊ុនដោយសារតែគ្មានការធ្វើគម្រោងថវិការ។

❖ ផលប៉ះពាល់វិជ្ជមាន (នៃការគ្មានគម្រោងថវិកា)

ទោះបីគ្មានគម្រោងថវិកាប្រចាំឆ្នាំក៏អាចមានផលវិជ្ជមានខ្លះៗនៅក្នុងបរិបទបច្ចុប្បន្ន ដោយឡែកពីផលអវិជ្ជមានជាច្រើន។ ផលវិជ្ជមានដែលអាចកើតមានរួមមាន៖

---

[9] រៀបរៀងដោយនិស្សិតឈ្មោះ ជីវ ម៉ីម៉ី, ស៊ឹម ស្រីពេជ, សុខ ផាណាត់, ថ្លាង សុខហេង, យាង លីឆេង. (២០២១). ប្រធានបទ៖ *អត្ថប្រយោជន៍នៃការរៀបចំគម្រោងចំណាយរបស់ ក្រុមហ៊ុនខ្មែរប៊ែវើរីជីស.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី១៩ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៤. ភ្នំពេញ។

[10] រៀបរៀងដោយនិស្សិតឈ្មោះ ស្មាន ដាវ៉ា, មុំ រតនា, ប្រៃ ស្រីឡឺ, គង់ វនីន. (២០២៣). ប្រធានបទ៖ *អត្ថប្រយោជន៍រៀបចំគម្រោងថវិការបស់ក្រុមហ៊ុន មេនូឡាយហ្វ៍.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៦. ភ្នំពេញ។

**១. បើកចំហទំនើបនិងភាពបត់បែនខ្ពស់**

អ្នកគ្រប់គ្រងអាចអនុវត្តការផ្លាស់ប្តូរយុទ្ធសាស្ត្រឬការចំណាយបានយ៉ាងរហ័ស ប្រសិនបើមានបម្រែបម្រួលក្នុងទីផ្សារ។

**២. កាត់បន្ថយពេលវេលា និងធនធានក្នុងការធ្វើផែនការ**

មិនចំណាយពេលធ្វើឯកសារយូរពេក ដូចជា តារាងថវិកា ឯកសារអនុម័តជាដើម។

**៣. អាចជម្រុញភាពច្នៃប្រឌិតបន្ថែម**

បុគ្គលិក ឬអ្នកគ្រប់គ្រងអាចនាំគ្នាជ្រើសយកវិធីសាស្ត្រថ្មីៗ ដោយគ្មានដែនកំណត់លើចំណាយពីផែនការដែលបានកំណត់ជាមុន។

**៤. ជម្រុញសកម្មភាពផ្ទាល់ខ្លួន (Initiative-based spending)**

អ្នកបំពេញការងារមានសិទ្ធិសម្រេចចិត្តលើការចំណាយជាផ្ទាល់ មានសេរីភាពផ្នែកផ្លូវចិត្ត ដោយផ្អែកលើតម្រូវការពិតប្រាកដ និងភ្លាមៗគ្មានសម្ពាធ[11]។

❖ **ផលប៉ះពាល់អវិជ្ជមាន (នៃការគ្មានគម្រោងថវិកា)**

ការគ្មានគម្រោងថវិកា អាចបង្កើតនូវអ្វីដែលខ្វះភាពស្ថិរភាព ហើយប៉ះពាល់ដល់ប្រតិបត្តិការជាច្រើនផ្នែក៖

**១. បាត់បង់ទិសដៅហិរញ្ញវត្ថុ**

- មិនអាចដឹងច្បាស់ថា ត្រូវចំណាយលើអ្វី និងក្នុងកម្រិតប៉ុន្មាន?

**២. ចំណាយលើអ្វីដែលមិនចាំបាច់ នឹងខ្ជះខ្ជាយធនធាន**

- ពិបាកក្នុងការប្រកាន់លើអាទិភាព នៃការចំណាយ។
- បណ្តាលឱ្យប៉ះពាល់ដល់អត្ថប្រយោជន៍សរុប។

**៣. គ្មានមូលដ្ឋានសម្រាប់វាយតម្លៃប្រសិទ្ធភាព**

- គ្មានគោលដៅថវិកាជាច្បាស់។
- ពិបាកវាយតម្លៃថា ប្រតិបត្តិការណាធ្វើបានល្អ ឬអត់។

**៤. បង្កើតបញ្ហា នៃការត្រួតពិនិត្យ និងរបាយការណ៍**

- គ្មានគម្រោងថវិកាមានន័យថា មិនអាចប្រៀបធៀបរបាយការណ៍ចំណាយបានសម្រេចការិយមុននឹងក្រោយ។

**៥. ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងភាពជឿជាក់**

- អាចបណ្តាលឱ្យដៃគូអាជីវកម្ម ឬអ្នកវិនិយោគ បាត់បង់ជំនឿលើស្ថាប័ន។

**៦. ប្រឈមនឹងគ្រោះថ្នាក់ហិរញ្ញវត្ថុ**

- កើតការខ្វះប្រាក់ ឬការប្រើប្រាស់មិនប្រសើរ អាចនាំដល់បំណុល ឬបញ្ហាជាបន្តបន្ទាប់[12]។

---

[11] រៀបរៀងដោយនិស្សិតឈ្មោះ ស្មាន ដារ៉ា, មុំ រតនា, ប្រៃ ស្រីឡី, គង់ វនីន. (២០២៣). ប្រធានបទ៖ *អត្ថប្រយោជន៍រៀបចំគម្រោងថវិការបស់ក្រុមហ៊ុន មេនូឡាយហ្វ៍.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៨. ភ្នំពេញ។

[12] រៀបរៀងដោយនិស្សិតឈ្មោះ សេន ធីម, ឡេង សុភា, ហាន មិនា, ភិ សុផា, ឃី គីមឆៃ. (២០២៣). ប្រធានបទ៖ *ការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន ភី ធី ស៊ី កុំព្យូទ័រ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៧. ភ្នំពេញ។

### ២.៣.២ ដំណើរការនៃការរៀបចំថវិកា

ដំណើរការរៀបចំថវិកាមានផលប៉ះពាល់សំខាន់ៗចំពោះសេដ្ឋកិច្ចសង្គម និងការគ្រប់គ្រងរដ្ឋបាល។ ខាងក្រោមនេះជាផលប៉ះពាល់សំខាន់ៗ៖

**១. ផលប៉ះពាល់ដល់សេដ្ឋកិច្ច**

- ចំណូលនិងចំណាយ៖ ការរៀបចំថវិកាធ្វើឱ្យមានការលាយគ្នារវាងចំណូល (ពន្ធអាករ ប្រាក់ចំណូលរដ្ឋ) និងចំណាយ (ការវិនិយោគ សុខុមាលភាពសង្គម) ដែលអាចប៉ះពាល់ដល់ស្ថិរភាពសេដ្ឋកិច្ច។
- ការវិនិយោគរដ្ឋ៖ ថវិកាដែលរៀបចំល្អអាចជំរុញការវិនិយោគរដ្ឋក្នុងសេដ្ឋកិច្ចដូចជា ឯកសណ្ឋានស្ថាបត្យកម្ម និងវិស័យសំខាន់ៗ[13]។
- អតិផរណា និងការលូតលាស់៖ ការចំណាយលើវិស័យជាក់លាក់អាចជំរុញការលូតលាស់សេដ្ឋកិច្ច ប៉ុន្តែការចំណាយមិនប្រក្រតីអាចបណ្តាលឱ្យមានអតិផរណា។

**២. ផលប៉ះពាល់ដល់សង្គម**

- សេវាសាធារណៈ៖ ថវិកានៅវិស័យសុខភាពអប់រំ និងសង្គមប៉ះពាល់ដល់គុណភាពជីវិតប្រជាពលរដ្ឋ។
- ការកាត់បន្ថយភាពក្រីក្រ៖ ការចំណាយលើកម្មវិធីសង្គមអាចជួយកាត់បន្ថយភាពក្រីក្រ និងបង្កើនឱកាសការងារ។
- ភាពសមធម៌ក្នុងសង្គម៖ ថវិកាដែលមានការចែកចាយសមហេតុសមផលអាចជួយបង្កើនសមភាពក្នុងសង្គម។

**៣. ផលប៉ះពាល់ដល់ការគ្រប់គ្រងរដ្ឋបាល**

- ប្រសិទ្ធភាពរដ្ឋ៖ ថវិកាដែលរៀបចំបានល្អជួយធានាឱ្យមានការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។
- ការរៀបចំអាទិភាព៖ រដ្ឋាភិបាលត្រូវកំណត់អាទិភាពលើវិស័យសំខាន់ៗ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍ។
- ភាពស្របច្បាប់ និងតម្លាភាព៖ ការរៀបចំថវិកាត្រូវមានតម្លាភាព និងការទទួលខុសត្រូវដើម្បីជៀសវាងអំពើពុករលួយ។

ការរៀបចំថវិកា ជាប្រភេទផែនការហិរញ្ញវត្ថុដែលសំខាន់សម្រាប់ការគ្រប់គ្រងប្រាក់ចំណូល និងការចំណាយ។ វាបានផ្តល់ឱ្យផលប៉ះពាល់ដូចខាងក្រោម៖

❖ **ផលប៉ះពាល់វិជ្ជមាន**

- ការគ្រប់គ្រងប្រាក់បានល្អ៖ ការរៀបចំថវិកាជួយអោយអ្នកដឹងថាប្រាក់ចំណូលត្រូវប្រើចំនួនប៉ុន្មាន និងប្រភេទចំណាយអ្វីខ្លះ។

---

[13] *Cambodia.ohchr.org*. (2025, June 30). *ការវិនិយោគរដ្ឋ.* Retrieved from https://cambodia.ohchr.org/sites/default/files/Social%20and%20Economic%20Impacts_KH.pdf

- ការបង្កើនសមតុល្យហិរញ្ញវត្ថុ៖ ជួយបង្ការការចំណាយលើអ្វីដែលមិនចាំបាច់ និងអាចសន្សំសំចៃបាន។
- ការបង្កើនសមតុល្យហិរញ្ញវត្ថុ៖ ជួយបង្ការការចំណាយលើអ្វីដែលមិនចាំបាច់ និងអាចសន្សំសំចៃបាន។
- ការកំណត់អាទិភាពលើការចំណាយ៖ អាចដាក់ចំណាយសំខាន់ៗ កាន់តែមានអាទិភាព ដូចជាការសិក្សា ឧបករណ៍ចាំបាច់ និងការវិនិយោគ។
- ការត្រៀមខ្លួនសម្រាប់អនាគត៖ ថវិកាជួយបង្កើតផែនការសន្សំ និងការវិនិយោគ ដើម្បីទប់ស្កាត់ហានិភ័យហិរញ្ញវត្ថុ។
- ការបង្កើនសុវត្ថិភាពហិរញ្ញវត្ថុ៖ ជួយបង្ការការខាតបង់ទឹកប្រាក់ដោយសារការចំណាយតាមបែបអារម្មណ៍។

❖ **ផលប៉ះពាល់អវិជ្ជមាន (បើមិនរៀបចំត្រឹមត្រូវ)**

- បណ្តាលឱ្យមានបំណុលកើនឡើង៖ បើគ្មានថវិកាត្រឹមត្រូវទេអ្នកអាច ចំណាយលើអ្វីដែលលើសពីសមត្ថភាព ហើយធ្វើឱ្យជាប់បំណុល។

សរុបរួមមក ដំណើរការរៀបចំថវិកាអាចមានប្រយោជន៍ ឬផលប៉ះពាល់អវិជ្ជមានពឹងផ្អែកលើវិធីសាស្រ្ត និងគោលនយោបាយរដ្ឋ។ ដូច្នេះ ត្រូវមានការរៀបចំប្រកបដោយការប្រក្រតីភាព ដើម្បីបង្កើនការលូតលាស់ និងសុខមាលភាពសង្គម[14]។

[14] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. *ដំណើរការនៃការរៀបចំថវិកា.* Retrieved 2025, June 30 from https://mef.gov.kh/assets/uploads/2025/01/Budget_In_Brief_2025_FInal.pdf

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

## ៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

**ក្រុមហ៊ុន ភីធីស៊ី កំព្យូទ័រ ខូល អិលធីឌី (PTC Computer Co.,ltd )** ត្រូវបានបង្កើតឡើងជាស្ថាប័នតូចមួយនៅក្រុងភ្នំពេញកាលពីឆ្នាំ **១៩៩៦** ដោយ **PTC** មានឈ្មោះពេញថា **Phsar Thmey Computer**។ ដោយចាប់ផ្តើមតាំងពីនៅជាអាជីវកម្មខ្នាតតូច ដែលជាប្រភេទក្រុមហ៊ុនអាជីវកម្មបែបលក្ខណៈគ្រួសាររហូតក្លាយទៅជាក្រុមហ៊ុនបែបស្តង់ដារដែលមានលោក អ៊ឹង សែ ជាអគ្គនាយកក្រុមហ៊ុនដោយមានភាគហ៊ុនចំនួន ១០០ភាគរយទាំងស្រុង។ ក្រុមហ៊ុន ភីធីស៊ី កំព្យូទ័រ ត្រូវបានគេចាត់ទុកថាជា **" ហាង IT ដែលគួរឱ្យទុកចិត្ត "** ដោយសារការផ្តល់សេវាកម្មល្អ រួមទាំងជាប្រភពផ្តល់ការធានា និងផលិតផលដ៏ត្រឹមត្រូវ ប្រសិនបើទោះបីជាមានអ្នកប្រើប្រាស់ខ្លះទទួចថាមានតម្លៃខ្ពស់ក៏ដោយ សេវាកម្មស្ទើយជាច្រើនបានបង្ហាញភាពជឿជាក់ពីអតិថិជននៅក្នុងនិងក្រៅប្រទេស។ ក្រុមហ៊ុន ភីធីស៊ី កំព្យូទ័រ ជាក្រុមហ៊ុនដែលផ្គត់ផ្គង់ទាំងសម្ភារៈបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសេវាកម្ម បើរាប់ចាប់ពីឆ្នាំ ១៩៩៦ មកដល់បច្ចុប្បន្ននេះមានរយៈពេល ២៩ឆ្នាំទៅហើយដោយឡែកការផ្គត់ផ្គង់របស់ក្រុមហ៊ុននេះសុទ្ធសឹងតែជាផលិតផលដែលមានគុណភាពល្អ ព្រមជាមួយនឹងការធានាត្រឹមត្រូវពីរោងចក្រ និងក្រុមការងារដែលមានជំនាញវិជ្ជាជីវៈយ៉ាងពិតប្រាកដដែលសមស្របទៅតាមរចនាសម្ព័ន្ធរបស់ខ្លួន ពោលគឺជួយបំលែងអាជីវកម្ម និងពង្រឹងជីវិតជាមួយផលិតផល IT ដែលមានគុណភាពលើកដំបូង និងផ្តល់សេវាកម្មល្អជូនអតិថិជន។ ដោយសារការរីកចម្រើនដោយរួមបញ្ចូលជាមួយការទទួលខុសត្រូវ និងការផ្តល់សេវាកម្មអតិថិជនដ៏ល្អបានធ្វើឱ្យ **PTC Computer Co.,ltd** ក្លាយជាមួយនៅក្នុងចំណោមហាងព័ត៌មានវិទ្យាដ៏ទូលំទូលាយនៅកម្ពុជា។ បន្ថែមពីនេះ **PTC Computer** បានក្លាយជាអាជីវកម្មធំទូលាយជាងមុន ដោយក្លាយជាក្រុមហ៊ុនដឹកជញ្ជូនផលិតផល IT ពីម៉ាកអន្តរជាតិ ច្រើនជាង ២៦ ដល់ ៣០ ម៉ាក ដូចជា Acer, Dell, HP, Lenovo, Asus, NEC, Epson និង Razer ។ ក្រុមហ៊ុនបានទទួលតំណែងជា Authorized Distributor និង Reseller សម្រាប់ម៉ាកធំៗ ដូចជា Apple, Microsoft, Cisco, VMware, SAP ព្រមទាំងវាយតម្លៃថា មានសេវាកម្មនិងផលិតផលដ៏ទូលំទូលាយជាសកល។ ក្រុមហ៊ុននេះក៏បានរៀបចំព្រឹត្តិការណ៍សំខាន់ៗមានដូចជា ពិធីអបអរសាទរ ខួប ២០ ឆ្នាំ នៅឆ្នាំ ២០១៦ ជាមួយការចូលរួមរបស់ពិធីកិត្តិយសផ្សេងៗ។ ធ្វើការរៀបចំព្រឹត្តិការណ៍ធានា Acer & Predator Dealer Event នៅឆ្នាំ ២០២២ ជាមួយលោក អ៊ឹង សែ និង លោកស្រី ឌីយាណា និងកិច្ចព្រមព្រៀងទទួលជាកម្មវិធីចែកចាយផ្លូវការសម្រាប់ AOC ឆ្នាំ ២០២៤ ។




PTC
COMPUTER

### ៣.១.២ ប្រវត្តិនិមិត្តសញ្ញាក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

ក្រុមហ៊ុន **PTC Computer Co., Ltd** បានមានការផ្លាស់ប្តូនិមិត្តសញ្ញាពីដង ដើម្បីបង្ហាញពីការរីកចម្រើននៃអាជីវកម្ម និងការចូលទៅក្នុងសតវត្សថ្មីនៃបច្ចេកវិទ្យា។

1. **ឆ្នាំ ១៩៩៦-២០២៣**

2. ឆ្នាំ ២០២៣-បច្ចុប្បន្ន

- ឆ្នាំ **១៩៩៦** ដល់ **២០២៣**: ស្លាកសញ្ញា **"PTC COMPUTER"** ចាស់ មានរង្វង់ និងពណ៌ចំរុះ។
- ថ្ងៃទី **២៥ ធ្នូ ២០២៣**: ស្លាកថ្មី Minimalist ស្រស់ស្អាត មានអក្សរ PTC ខ្មៅ/ខៀវ។
- ចុះផ្នែកទស្សនានីមួយៗពិតប្រាកដថា មានការផ្លាស់ប្តូរ ម្តងតែប៉ុណ្ណោះ នៅឆ្នាំ ២០២៣ ។

### ៣.១.៣ អំពីក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

**PTC Computer Co., Ltd** គឺជាក្រុមហ៊ុនឯកជនមួយនៅកម្ពុជាដែលមានជំនាញខាងផ្គត់ផ្គង់នូវផលិតផលបច្ចេកវិទ្យាទំនើបដូចជា៖

- គ្រឿងកុំព្យូទ័រ និង **Laptop**
- គ្រឿងបន្លាស់ **Hardware & Software**

- សេវាកម្មជួសជុល និង **Maintenance**
- **Networking Systems** និង **CCTV Security**
- **IT Solutions** សម្រាប់អាជីវកម្មនានា

ក្រុមហ៊ុននេះបើកដំណើរការមកជាយូរឆ្នាំ មានការជឿទុកចិត្តខ្ពស់ពីអតិថិជនជាច្រើនទាំងក្នុងវិស័យរដ្ឋ និងឯកជន។

**ក. <u>បេសកកម្មរបស់ក្រុមហ៊ុន</u>**

ក្រុមហ៊ុន ភីធីស៊ី មានបេសកកម្មធ្វើឱ្យការផ្តល់នូវផលិតផលបច្ចេកវិទ្យាលំដាប់ពិភពលោក ដើម្បីជាដំណោះស្រាយ និងសេវាកម្មប្រកបដោយនិរន្តរ៍ភាពនៅក្នុងទីផ្សារដែលបានជ្រើសរើសរបស់យើងដោយបង្កើតតម្លៃភាគទុនិកខ្ពស់។

**ខ. <u>ចក្ខុវិស័យរបស់ក្រុមហ៊ុន</u>**

ក្រុមហ៊ុន **ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី** ធ្វើឱ្យជីវិតកាន់តែប្រសើរ និងធ្វើឱ្យមានការផ្លាស់ប្តូរអាជីវកម្មសម្រាប់អតិថិជនរបស់យើង ដោយមានភាពជាអ្នកដឹកនាំនៅក្នុងបច្ចេកវិទ្យា និងទីផ្សារដែលបានជ្រើសរើស និងក្លាយជាជម្រើសទី១សម្រាប់អតិថិជន និងដៃគូសហការដោយមានការប្តេជ្ញាចិត្ត ដើម្បីនិរន្តភាពក្នុងការផ្តល់ដំណោះស្រាយបច្ចេកវិជ្ជា **(IT Solutions)** នៅក្នុងប្រទេសកម្ពុជា។

**គ. <u>គោលដៅរបស់ក្រុមហ៊ុន</u>**

ក្រុមហ៊ុន ភីធីស៊ី តែងតែឈានមុខគេទាំងផលិតផល និងសេវាកម្ម។ គោលដៅចម្បងរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី គឺសម្រេចយ៉ាងពិតប្រាកដនូវ ទស្សនៈវិស័យ និងបេសកកម្ម។

**<u>ឃ.រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ</u>**

1. **អ្នកឧកញ៉ា អ៊ឹង សែ ( Neak Oknha Ung Se )**

**Chairman**



លោកជា **Chairman** នៃក្រុមហ៊ុន **PTC Computer Co., Ltd** និងជាអតីតប្រធានក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានប្រកាសឱ្យប្រើមុខងារដែលជាអ្នកដឹកនាំនេះមកទល់តែបច្ចុប្បន្នទេ។ លោកបានទទួលកិត្តិយសជាអ្នកឧកញ៉ា ពីព្រះមហាក្សត្រកម្ពុជា នៅថ្ងៃទី ១៨ សីហា ២០២៣ ដូចគ្នា។ មិនតែប៉ុណ្ណោះលោកក៏បានត្រូវបានតែងតាំងជាអ្នកជួយជនរាជពីនាយករដ្ឋមន្ត្រី **Hun Manet** (១៩ កញ្ញា ២០២៤)។ លោកជាអ្នកស្ថាបនារួមរបស់ **PTC Computer Co., ltd** ចាប់តាំងពីឆ្នាំ

១៩៩៦ រហូតមកដល់សព្វថ្ងៃ ក្រុមហ៊ុននេះបានក្លាយជាក្រុមហ៊ុនធំមួយនៃប្រទេសកម្ពុជាក្នុងការទិញ លក់ទិន្នន័យព័ត៌មានតាមរយៈបច្ចេកវិទ្យា។



2. លោកស្រី វូជលី តាំង **( Wouchlay Tang/ Diana )**



លោកស្រីមានតួនាទីជា អគ្គនាយិកា និងអ្នកស្ថាបនារួមនៃ **PTC Computer Co., Ltd** ដោយបានដឹកនាំដំណើរការក្រុមហ៊ុនភីធីស៊ីចាប់ពីឆ្នាំ ១៩៩៦ (២៩ ឆ្នាំហើយ) កិត្តិយសអ្នកឧកញ៉ារបស់លោកស្រីក៏ទទួលបានដូចស្វាមីរបស់ខ្លួនដែរ។

តួនាទីផ្សេងទៀតលោកស្រីជាប្រធាន **PTC Group** និងក៏អ្នកដឹកនាំក្រុមហ៊ុនផ្សេងទៀត ដោយមានដៃគូរជាស្វាមីជាអ្នកដឹកនាំគឺ លោកឧកញ៉ា **អ៊ឹង សែ** (Chairman)។

លោកអ៊ឹងសែ តែងបង្ហាញខ្លួនជាញឹកញាប់នៅក្នុងព្រឹត្តិការណ៍សាធារណៈជាច្រើនជាមួយ នឹងភរិយា លោកស្រី វូជលី តាំង ។



- វិស័យបច្ចេកវិទ្យា និងភាពជាអ្នកនាំមុខរបស់លោកឧកញ៉ា អ៊ឹង សែ និងអ្នកឧកញ៉ា វ៉ូដលី តាំង
    - នៅថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុន PTC Computer បានចុះកិច្ចព្រមព្រៀងជាមួយ DataStax ដើម្បីយកបច្ចេកវិទ្យា AI (Generative AI) មកបញ្ចូលក្នុងគេហទំព័រ និងកម្មវិធី (App) របស់ខ្លួន។ នេះជាការបង្ហាញពីចក្ខុវិស័យរបស់អ្នកដឹកនាំក្នុងការចូលរួមក្នុងការបំលែងឌីជីថលនៅកម្ពុជា។
    - នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២៤, PTC ត្រូវបានតែងតាំងជាអ្នកចែកចាយផ្លូវការនៃផលិតផល AOC All-In-One Desktop នៅកម្ពុជា។ បង្ហាញពីសមត្ថភាពនាំចូលបច្ចេកវិទ្យាថ្មីៗមកកាន់ទីផ្សារកម្ពុជាយ៉ាងសកម្ម។

ការចូលរួមព្រឹត្តិការណ៍ជាសាធារណៈ: នៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២៤, អ្នកដឹកនាំ PTC បានចូលរួមក្នុងព្រឹត្តិការណ៍នេះជាមួយនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ដោយរៀបចំដោយសមាគមសិល្បករ។ បង្ហាញពីភាពជាដៃគូរជាតិ និងការគាំទ្រព្រឹត្តិការណ៍សង្គម-វប្បធម៌។ បន្ថែមពីនេះទៅទៀត នៅឆ្នាំ ២០១៦ ក្រុមហ៊ុនភីធីស៊ី បានប្រារព្ធខួបគ្រប់ ២០ឆ្នាំ ដោយមានការចូលរួមពីភ្ញៀវកិត្តិយស និងអ្នកគ្រប់គ្រងល្បីៗជាច្រើនរូប។ ក៏ដូចជាសកម្មភាពសង្គមជាច្រើនដែលលោក អ៊ឹង សែនិង ភរិយាបានចូលរួម។

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤, PTC Group បានរៀបចំកម្មវិធីបរិច្ចាគឈាមជាសាធារណៈ ដោយមានអ្នកដឹកនាំកំពូលចូលរួមផ្ទាល់។ ហើយនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២៤, លោក អ៊ឹង សែ និង លោកស្រី វ៉ូដលី តាំង បានអនុវត្តកម្មវិធីបរិច្ចាគ ដើម្បីជួយសង្គម បើទោះបីព័ត៌មានលម្អិតអំពីអ្នកទទួលអំណោយមិនបានបង្ហាញច្បាស់លាស់ក៏ដោយ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ លោកនិងភរិយា បានផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក តាមរយៈការជួយគាំទ្រឱ្យពួកគេខិតខំបំពេញការងារបានកាន់តែប្រសើរ និងបានបង្កើតជាភាពពេញចិត្តនឹងការសម្រេចបានស្នាដៃនូវការងាររបស់ខ្លួន និងជួយជំរុញឱ្យមានឱកាសការងារជាច្រើន។

## ៣.២ យុទ្ធសាស្ត្រការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី

បន្ទាប់ពីការសិក្សា និងវិភាគយ៉ាងប្រុងប្រយ័ត្ន យើងខ្ញុំបានស្វែងយល់អំពីយុទ្ធសាស្ត្រក្នុងការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន **PTC Computer Co., Ltd.** ដែលជាក្រុមហ៊ុនឯកជនបម្រើផ្នែកពាណិជ្ជកម្មគ្រឿងកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាននៅទីផ្សារកម្ពុជា។ គោលបំណងសំខាន់នៃយុទ្ធសាស្ត្រនេះគឺដើម្បីធានាឱ្យមានប្រសិទ្ធភាពក្នុងការប្រមូល បែងចែក និងគ្រប់គ្រងថវិកា ដោយផ្អែកលើគោលនយោបាយហិរញ្ញវត្ថុ និងផែនការអភិវឌ្ឍរបស់ក្រុមហ៊ុន។

ការរៀបចំគម្រោងថវិកានេះត្រូវបានអនុវត្តដោយការចូលរួមពីផ្នែកគ្រប់គ្រងនីតិវិធី ផ្នែកលក់ ផ្នែកផ្គត់ផ្គង់ និងផ្នែកហិរញ្ញវត្ថុ ដើម្បីធានាថា ថវិកាត្រូវបានរៀបចំយ៉ាងជាក់លាក់ ត្រឹមត្រូវ និងអាចវាស់វែងបាន។ ការទាញយកទិន្នន័យប្រវត្តិសាស្ត្រនៃប្រាក់ចំណេញចំណាយការព្យាករណ៍ប្រាក់ចំណូលនាពេលអនាគត និងការវិភាគលើបរិយាកាសទីផ្សារ ជាជំហានសំខាន់ក្នុងដំណើរការនេះ។

ក្នុងបរិបទនៃការប្រកួតប្រជែងខ្លាំង និងបច្ចេកវិទ្យាកាន់តែចុងក្រោយ ការមានយុទ្ធសាស្ត្រថវិកាដែលមានសុវត្ថិភាព អាចបត់បែនតាមស្ថានភាព និងអាចប្រើប្រាស់បានជាក់ស្តែង គឺជាឧបករណ៍មួយសំខាន់ក្នុងការទទួលបានភាពជោគជ័យ និងភាពរឹងមាំរបស់ក្រុមហ៊ុនក្នុងទីផ្សារ។

**៣.២.១ ភាពចាំបាច់នៃការរៀបចំគម្រោងចំណាយរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី**

ក្នុងដំណើរការគ្រប់គ្រងអាជីវកម្មឱ្យមានប្រសិទ្ធភាពនាពេលបច្ចុប្បន្នការរៀបចំគម្រោងថវិកាត្រូវបានគេចាត់ទុកថាជាឧបករណ៍គ្រប់គ្រងមួយដ៏សំខាន់ដែលអាចជួយឱ្យអង្គភាពអាជីវកម្ម មានទិសដៅបានយ៉ាងច្បាស់លាស់ និងអភិវឌ្ឍលើគោលដៅរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព។ សម្រាប់ក្រុមហ៊ុន **PTC Computer Co., Ltd.** ការរៀបចំគម្រោងថវិកាមានភាពចាំបាច់យ៉ាងខ្លាំង ដោយសារតែវាជាផ្នែកមួយ នៃការទ្រទ្រង់ផែនការយុទ្ធសាស្ត្ររយៈពេលខ្លី និងវែងដែលនាំឱ្យការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុកើតមានប្រកបដោយវិជ្ជាជីវៈ និងការរំពឹងទុក។ ថវិកាដែលបានរៀបចំល្អ និងមានប្រព័ន្ធតាមដានល្អ អាចជួយក្រុមហ៊ុនក្នុងការចំណាយយ៉ាងសមរម្យ បញ្ចេញគម្រោងវិនិយោគបានត្រឹមត្រូវ ក៏ដូចជាការជៀសវាងការបាត់បង់នូវធនធានមិនចាំបាច់។ លើសពីនេះទៅទៀតការរចនាថវិកាជាជំហានមួយដ៏សំខាន់ក្នុងការកសាងជំនឿចិត្តពីភាគីដទៃ និងការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ក្រុមហ៊ុននៅក្នុងទីផ្សារបច្ចេកវិទ្យាដ៏សម្បូរបែបនៅកម្ពុជា។ ដោយសារតែជាចំណុចគន្លឹះក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ សេចក្តីស្រាវជ្រាវនេះសង្ឃឹមថានឹងបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការរៀបចំគម្រោងថវិកាដែលមានប្រសិទ្ធភាព និងតួនាទីរបស់វាក្នុងការជួយឱ្យអាជីវកម្មអាចឈានទៅមុខបានប្រកបដោយទំនួលខុសត្រូវ និងចក្ខុវិស័យ។ ការគ្រប់គ្រងចំណាយ គឺជាតម្រូវការដែលមានការប្រុងប្រយ័ត្នខ្លាំង និងមានការយកចិត្តទុកដាក់ខ្ពស់ ព្រោះវាប្រៀបដូចជា សរសៃឈាមរបស់ក្រុមហ៊ុន។ ប្រសិនបើសរសៃឈាមមួយណាដាច់ ឬខូចខាតវាអាចបណ្តាលឱ្យមានការកកស្ទះនូវដំណើរអាជីវកម្ម ហើយអាចបណ្តាលឱ្យមានបញ្ហាហិរញ្ញវត្ថុនៅក្នុងក្រុមហ៊ុនផងដែរ។ ការរៀបចំគម្រោងថវិកា គឺជាដំណើរការសំខាន់មួយដែលមានភាពសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធានាថាការប្រើប្រាស់ធនធានមានប្រសិទ្ធភាព និងចំណាយត្រឹមត្រូវ។ សម្រាប់ក្រុមហ៊ុន **PTC Computer Co., Ltd.** ការរៀបចំគម្រោងថវិកាជួយធានាឱ្យមានភាពច្បាស់លាស់ក្នុងការកំណត់ទិសដៅហិរញ្ញវត្ថុ និងការធ្វើផែនការដើម្បីបំពេញគោលបំណងអាជីវកម្ម។

ការរៀបចំគម្រោងថវិកាអាចជួយក្រុមហ៊ុនក្នុងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ការបង្ហាញទិសដៅសំខាន់សម្រាប់ការវិនិយោគ និងជំរុញការអភិវឌ្ឍទ្រព្យសម្បត្តិឱ្យមានប្រសិទ្ធភាព។ លើសពីនេះ ការរៀបចំគម្រោងថវិកាក៏ជួយបង្កើនភាពទំនុកចិត្តពីភាគីវិនិយោគ និងដៃគូអាជីវកម្ម ដែលជាសារសំខាន់ក្នុងការកសាងសម្ព័ន្ធភាពដ៏រឹងមាំ និងការរីកចម្រើនរយៈពេលវែង។

- សារៈសំខាន់នៃការរៀបចំគម្រោងថវិកាមានដូចជា៖

**១. ជួយកំណត់ទិសដៅហិរញ្ញវត្ថុ**

គម្រោងថវិកាជួយកំណត់បរិមាណ និងគោលបំណងនៃការចំណាយ និងចំណូល ដែលធ្វើឱ្យក្រុមហ៊ុនមានទិសដៅច្បាស់លាស់សម្រាប់ការដំណើរការ និងការអភិវឌ្ឍ។

**២. បង្កើនប្រសិទ្ធភាពការប្រើប្រាស់ធនធាន**

ដោយមានផែនការថវិកា ក្រុមហ៊ុនអាចវាយតម្លៃ និងត្រួតពិនិត្យចំណាយ បណ្តាលឱ្យការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងសមរម្យ។

**៣. ជួយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ**

ការរៀបចំគម្រោងថវិកាធ្វើឱ្យក្រុមហ៊ុនអាចទស្សនាបានថានឹងមានការចំណាយ និងប្រាក់ចំណូលនៅកន្លែងណាដែលជួយក្នុងការគ្រប់គ្រងហានិភ័យ និងការចរចារប្រាក់។

**៤. ជួយសម្រេចចិត្តយុទ្ធសាស្ត្រហិរញ្ញវត្ថុ**

គម្រោងថវិកាជាគន្លងសំខាន់សម្រាប់ការសម្រេចចិត្តលើការវិនិយោគ ការកែលម្អ និងការពង្រីកអាជីវកម្ម។

**៥. បង្កើនភាពទំនុកចិត្តពីភាគីវិនិយោគ និងដៃគូ**

ការរៀបចំគម្រោងថវិកាត្រឹមត្រូវ បង្ហាញពីភាពជាអាជីវកម្មដែលមានការគ្រប់គ្រងយ៉ាងម៉ត់ចត់ និងមានវិស័យហិរញ្ញវត្ថុរឹងមាំដែលជួយបង្កើនទំនុកចិត្តពីភាគីដែលពាក់ព័ន្ធ។

**៦. ជួយទប់ស្កាត់បញ្ហាសេដ្ឋកិច្ច និងការប្រែប្រួលទីផ្សារ**

ការរៀបចំគម្រោងថវិកាពីរយៈពេលវែង អាចជួយក្រុមហ៊ុនឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះការប្រែប្រួលផែនការសេដ្ឋកិច្ច និងបរិយាកាសទីផ្សារ។

ដូច្នេះក្រុមហ៊ុន **ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី** នៅតែបន្តកាត់បន្ថយ និងត្រួតពិនិត្យហានិភ័យដើម្បីទទួលបានប្រាក់ចំណូលខ្ពស់បំផុត។ រាល់ការចំណាយច្រើនរបស់ក្រុមហ៊ុន គឺស្ថិតនៅដើមខែដែលមានតម្រូវការច្រើនក្នុងការចំណាយទៅលើប្រតិបត្តិការដែលក្រុមហ៊ុនតែងតែយកចិត្តទុកដាក់ជានិច្ចទៅលើការចំណាយណាដែលគួរកាត់បន្ថយ និងចំណាយណាដែលមិនគួរចំណាយ តទៅទៀតប្រសិនបើមិនផ្តល់ផលចំណេញដល់ក្រុមហ៊ុន ដើម្បីធានាបាននូវនិរន្តរ៍ភាពក្នុងដំណើរការអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុនបានកំណត់នូវគោលការណ៍គ្រប់គ្រងចំណាយយ៉ាងច្បាស់លាស់ ព្រោះជាផ្នែកមួយដែលសំខាន់ដើម្បីងាយស្រួលក្នុងការបំពេញតម្រូវការរបស់អតិថិជនទាន់ពេលវេលា។ ក្រុមហ៊ុនបានបែងចែកចំណាយជាពីរផ្នែកដូចខាងក្រោម៖

សរុបជារួមការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន ភី ធី ស៊ីកុំព្យូទ័រ ស្ថិតនៅក្រោមការឃ្លាំមើលរបស់ថ្នាក់ដឹកនាំ និង ការប្រុងប្រយ័ត្នពីប្រធានសាខាជានិច្ចដើម្បី ឱ្យតាមសាខាមានការចំណាយឱ្យបានសមស្របទៅតាមកាលៈទេសៈជៀសវាងបង្ករឱ្យមានហានិភ័យ ឬការខាតបង់ចំពោះក្រុមហ៊ុន ។

**៣.២.២ ការរៀបចំគម្រោងចំណាយរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូ អិលធីឌី**

ការរៀបចំគម្រោងចំណាយគឺជាផ្នែកសំខាន់មួយនៃការគ្រប់គ្រងហិរញ្ញវត្ថុដែលជួយឱ្យក្រុមហ៊ុន **PTC Computer Co., Ltd.** អាចបែងចែកធនធានបានយ៉ាងមានប្រសិទ្ធភាព គ្រប់គ្រងការចំណាយនិងគាំទ្រគោលបំណងយុទ្ធសាស្ត្រអាជីវកម្ម។ ក្រុមហ៊ុនបានអនុវត្តវិធានការមួយជាស្វ័យប្រវត្តិ និងមានរចនាសម្ព័ន្ធដែលសម្របសម្រួលទៅតាមតម្រូវការប្រតិបត្តិការ និងផែនការលូតលាស់រយៈពេលវែង។ មូលហេតុដែលក្រុមហ៊ុនត្រូវរៀបចំគម្រោងចំណាយពីព្រោះវាអាចផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងព័ត៌មានទិន្នន័យរបស់ថវិកាចរន្តឬថវិកាមូលធននិង ជួយកាត់បន្ថយការចំណាយពេលវេលាក្នុងការរៀបចំកែតម្រូវទិន្នន័យនៅពេលមានការកែប្រែលើផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល និងគម្រោងចំណូលចំណាយថវិកាប្រចាំឆ្នាំ បន្ទាប់ពីមានការសម្រេចឯកភាពកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផ្តល់ភាពងាយស្រួលសម្រាប់ការត្រួតពិនិត្យ និងតាមដានរាល់ការចំណាយរបស់អង្គភាពថវិកានីមួយៗដែលឱ្យយើងដឹងពីការចំណាយមិនចំគោលដៅ ឬមិនស្របទៅតាមសូចនាករដែលបានកំណត់ក្នុងឆ្នាំឬមិនស្របទៅតាម ស្មារតីនៃការចរចាថវិកាប្រចាំឆ្នាំរវាងក្រសួង និងស្ថាប័នជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការគ្រប់គ្រងគម្រោងចំណាយ វាពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុននានា ពីព្រោះបើសិនជាយើងមិនបានត្រួតពិនិត្យឱ្យបានច្បាស់លាស់ទេនោះ គឺនឹងធ្វើឱ្យប៉ះពាល់ទៅដល់ក្រុមហ៊ុនប្រាកដណាស់ ដូច្នេះហើយទើបក្រុមហ៊ុននីមួយៗតែងតែមានការគ្រប់គ្រងចំណាយសម្រាប់ក្រុមហ៊ុនត្រូវមានការរៀបចំគម្រោងចំណាយសម្រាប់ពេលអនាគត ដើម្បីកំណត់នៅគោលដៅជាក់លាក់ណាមួយក្នុងប្រតិបត្តិការទូទៅរបស់អង្គភាព។

**១. ការបែងចែកចំណាយយ៉ាងច្បាស់លាស់**

ចំណាយត្រូវបានចាត់ថ្នាក់ដោយផ្អែកលើធម្មជាតិ និងមុខងាររបស់វាក្នុងក្រុមហ៊ុន ដើម្បីងាយស្រួលក្នុងការតាមដាន និងគ្រប់គ្រងបានយ៉ាងមានប្រសិទ្ធភាព ជួយបង្កើតភាពច្បាស់លាស់ និងទំនួលខុសត្រូវ។

**២. ការព្យាករណ៍ដោយផ្អែកលើទិន្នន័យ**

ក្រុមហ៊ុនធ្វើការវិភាគទិន្នន័យហិរញ្ញវត្ថុអតីតកាលយ៉ាងម៉ត់ចត់ដើម្បីរកឃើញគំរូចំណាយ និងបង្កើតការព្យាករណ៍ចំណាយក្នុងអនាគតដោយផ្អែកលើមូលដ្ឋានទិន្នន័យពិត។

**៣. ការសហការជាមួយផ្នែកផ្សេងៗ**

ផ្នែកហិរញ្ញវត្ថុធ្វើការសហការយ៉ាងខ្លាំង ជាមួយនឹងផ្នែកប្រតិបត្តិការផ្សេងៗដើម្បីប្រមូលព័ត៌មាន និងរៀបចំគម្រោងចំណាយដែលមានភាពទូលំទូលាយ និងសមស្របទៅតាមតម្រូវការ។

**៤. ការសម្របសម្រួលទៅនឹងគោលដៅយុទ្ធសាស្ត្រ**

ការរៀបចំគម្រោងចំណាយត្រូវបានសម្របសម្រួលឱ្យស្របទៅនឹងគោលបំណងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ដើម្បីឱ្យការចំណាយសមរម្យក្នុងការផលិតចំណេញ និងពង្រឹងស្ថានភាពប្រកួតប្រជែង។

**៥. ការត្រួតពិនិត្យ និងគ្រប់គ្រងជាបន្តបន្ទាប់**

មានការតាមដានលើការចំណាយពិតប្រាកដ និងប្រៀបធៀបជាមួយថវិកាប៉ាន់ស្មាន ដើម្បីធានាថា ការចំណាយត្រូវបានគ្រប់គ្រងបានយ៉ាងត្រឹមត្រូវ ហើយអាចធ្វើវិធានការកែសម្រួលឱ្យទាន់ពេលវេលា។

**៦. ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ**

ក្រុមហ៊ុនបានយកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឌីជីថលមកប្រើ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការតាមដាន និងរាយការណ៍ចំណាយ ជួយសម្រេចបានការសម្រេចចិត្តដោយមានតុល្យភាព និងភាពច្បាស់លាស់។

ការរៀបចំគម្រោងចំណាយរបស់ក្រុមហ៊ុ **PTC Computer Co., Ltd.** ដូច្នេះ គឺជាគន្លងសំខាន់មួយដែលធានាឱ្យក្រុមហ៊ុនអាចដំណើរការបានយ៉ាងមានប្រសិទ្ធភាព និងអាចឆ្លើយតបទៅនឹងបរិយាកាសទីផ្សារដែលផ្លាស់ប្តូរបានយ៉ាងឆាប់រហ័ស។

**៣.២.៣ ប្រភពចំណាយ និងការត្រួតពិនិត្យចំណូលចំណាយរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូអិលធីឌី**

**ក. ប្រភពចំណាយ**

**ចំណាយ** គឺជាចលនាចេញ នៃសាច់ប្រាក់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិផ្សេងៗ ឬជាការលេចឡើងនូវបំណុលក្នុងការិយបរិច្ឆេទគណនេយ្យណាមួយដែលលេចឡើងពីការប្រគល់ទំនិញ ឬសេវាកម្មផ្សេងៗដែលផ្សំឡើងពីប្រតិបត្តិការកណ្តាល ឬប្រតិបត្តិការសំខាន់ៗជាច្រើនបន្តបន្ទាប់របស់អង្គភាពអាជីវកម្ម។

**ចំណាយ** គឺជាថ្លៃដើមទំនិញដែលបានលក់ និងការផ្តល់សេវាកម្មនៅក្នុងកំឡុងពេលខួបនៃគណនេយ្យ។

ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **PTC Computer Co., Ltd.** ប្រភពចំណាយ និងការត្រួតពិនិត្យចំណូលចំណាយ គឺជាផ្នែកមួយដ៏សំខាន់ដែលធានាឱ្យមានការប្រតិបត្តិការត្រឹមត្រូវ និងប្រសិទ្ធភាព។ ក្រុមហ៊ុនបានបែងចែកចំណាយមកពីប្រតិបត្តិការប្រចាំថ្ងៃ និងការវិនិយោគក្នុងការអភិវឌ្ឍអាជីវកម្មនៅក្នុង ការត្រួតពិនិត្យចំណូលចំណាយក្រុមហ៊ុនប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយមានការត្រឹមត្រូវ និងស្វ័យប្រវត្តិដើម្បីធានាថាការចំណាយ និងចំណូលត្រូវបានតាមដានយ៉ាងម៉ត់ចត់ និងមានប្រសិទ្ធភាព។ ការរាយការណ៍ និងការវិភាគចំណូល-ចំណាយត្រូវបានធ្វើជាប្រចាំ ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនអាចធ្វើការកែសម្រួល និងសម្រេចចិត្តយុទ្ធសាស្ត្របានត្រឹមត្រូវក្នុងការរក្សាសមតុល្យហិរញ្ញវត្ថុនិង ពង្រីកកំណើន។ ដោយឡែកការគ្រប់គ្រងប្រភពចំណាយ និងការត្រួតពិនិត្យចំណូល ចំណាយជាប្រព័ន្ធជាបន្តបន្ទាប់ក៏ជាកត្តាសំខាន់ក្នុងការធានាថាក្រុមហ៊ុនអាចបន្តលូតលាស់យ៉ាងរឹងមាំ ទប់ស្កាត់បញ្ហាសេដ្ឋកិច្ច និងបង្កើតចក្ខុវិស័យអាជីវកម្មច្បាស់លាស់សម្រាប់អនាគត។ ហេតុនេះហើយទើបនាងខ្ញុំសូមធ្វើការលើកឡើងនូវចំណាយ របស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ មកធ្វើការបកស្រាយដូចខាងក្រោម៖

- ចំណាយហានិភ័យៈគឺជាចំណាយដែលប្រើប្រាស់សម្រាប់បម្រុងទុកនៅពេលទំនិញមានបញ្ហានៅពេលកម្ម៉ង់ ។
- ចំណាយថ្លៃផុតកំណត់ធានាៈគឺជាចំណាយដែលក្រុមហ៊ុនប្រើប្រាស់សម្រាប់បម្រុងទុកដើម្បីទូទាត់ដល់អតិថិជននៅពេលមានបញ្ហា(ទំនិញខូចខាតគុណភាព និងបាត់បង់សោភ័ណ្ឌភាព)។
- ចំណាយលើប្រតិបត្តិការនិងរដ្ឋបាលៈគឺជាចំណាយដែលទាក់ទងនឹងការ គ្រប់គ្រងអាជីវកម្មប្រចាំថ្ងៃមានដូចជាៈ
  - ចំណាយប្រាក់ឈ្នួល និងអត្ថប្រយោជន៍ប្រចាំឆ្នាំរបស់បុគ្គលិក
  - ចំណាយកម្រៃជើងសារ និងការលក់ផលិតផល
  - ចំណាយលើការផ្សព្វផ្សាយផលិតផល ដោយការធ្វើពាណិជ្ជកម្ម
  - ចំណាយលើសម្ភារៈ និងឧបករណ៍ប្រើប្រាស់ក្នុងការបម្រើការងារផ្សេងៗ
  - ចំណាយជួលទីតាំង ទឹក ភ្លើង
  - ចំណាយជុសជុល និងការថែទាំ
  - ចំណាយលើពន្ធប្រចាំខែ ប្រចាំឆ្នាំ បសស។

សេចក្តីស្រាវជ្រាវនេះបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រងប្រភពចំណាយនិង ការត្រួតពិនិត្យចំណូល-ចំណាយ ដែលជាគន្លងសំខាន់សម្រាប់ភាពរឹងមាំ និងការលូតលាស់យូរអង្វែងរបស់ក្រុមហ៊ុន **PTC Computer Co., Ltd**. នៅក្នុងបរិយាកាសទីផ្សារបច្ចេកវិទ្យាដែលប្រកួតប្រជែងខ្លាំងនៅសព្វថ្ងៃ។

## ៣.៣ ផលប៉ះពាល់នៃការគ្មានគម្រោងថវិកា

ការមិនមានដំណើរការនៃការរៀបចំថវិកាអាចមានផលវិបាកអវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅដល់ក្រុមហ៊ុន អាជីវកម្ម រដ្ឋាភិបាល និងអង្គការនានា។

ផលវិបាកដែលអាចកើតមានមួយចំនួននៃការមិនមានដំណើរការថវិការួមមាន:

• កង្វះលទ្ធភាពមើលឃើញផ្នែកហិរញ្ញវត្ថុៈ បើគ្មានដំណើរការរៀបចំថវិកាទេវាមានភាពមើលឃើញ មានកម្រិតចំពោះប្រាក់ចំណូល ការចំណាយ និងលំហូរសាច់ប្រាក់។ កង្វះតម្លាភាពនេះអាចនាំឱ្យមានភាពមិនច្បាស់លាស់ផ្នែកហិរញ្ញវត្ថុ ការសម្រេចចិត្តមិនល្អជាដើម និងការលំបាកក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។

• ការបែងចែកធនធានគ្មានប្រសិទ្ធភាពៈ ជួយបែងចែកធនធានដោយផ្អែកលើ អាទិភាព គោលដៅ និងគោលដៅជាយុទ្ធសាស្ត្រ ។ បើគ្មានដំណើរការរៀបចំថវិកាទេធនធានអាចត្រូវបាន បែងចែកទៅតាមតម្រូវការឬ ផ្អែកលើតម្រូវការរយៈពេលខ្លីជាជាងអាទិភាពរយៈពេលវែង ដែលនាំទៅរកភាពគ្មានប្រសិទ្ធភាពនិងបាត់បង់ឱកាស។

• ភាពលំបាកក្នុងការរៀបចំផែនការ និងការព្យាករណ៍ៈ ដំណើរការថវិកាផ្តល់នូវក្របខណ្ឌសម្រាប់ការ ធ្វើផែនការ និងការព្យាករណ៍លទ្ធផលហិរញ្ញវត្ថុ ការកំណត់គោលដៅ និងការត្រួតពិនិត្យវឌ្ឍនភាព។ បើគ្មានដំណើរការរៀបចំថវិកាទវាក្លាយជាបញ្ហាប្រឈមក្នុងការរៀបចំផែនការអនាគតសម្រាប់ ប្រមើលមើលតម្រូវការហិរញ្ញវត្ថុ ឬធ្វើការសម្រេចចិត្តដែលមានព័ត៌មានដោយផ្អែកលើទិន្នន័យហិរញ្ញវត្ថុ។

ហានិភ័យនៃការចំណាយលើស និងបំណុល ៖ បើគ្មានដំណើរការរៀបចំថវិកាដើម្បីតាមដាន និង គ្រប់គ្រងការចំណាយទេ វាមានហានិភ័យខ្ពស់នៃការចំណាយលើស ការប្រមូលបំណុល និងជួបប្រទះការ លំបាកផ្នែកហិរញ្ញវត្ថុ។ ការមានការកង្វះវិន័យថវិកាអាចនាំឱ្យមានអស្ថិរភាពហិរញ្ញវត្ថុ និងបញ្ហាលំហូរសាច់ប្រាក់។

គណនេយ្យភាពនិង ការធ្វើការវាស់វែងការអនុវត្តមានកម្រិត៖ ដំណើរការថវិកាជួយបង្កើតគណនេយ្យភាពសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុកំណត់ការរំពឹងទុកច្បាស់លាស់ និងវាស់វែងលទ្ធផលធៀបនឹងគោលដៅ។ បើគ្មានដំណើរការរៀបចំថវិកាទេអាចនឹងមានការខ្វះខាតគណនេយ្យភាពតម្លាភាព ការវាស់វែងនិងការអនុវត្តដែលធ្វើឱ្យពិបាកក្នុងការវាយតម្លៃវឌ្ឍនភាព និងធ្វើការកែតម្រូវចាំបាច់។

ខកខានឱកាសសម្រាប់ការសន្សំ និងការវិនិយោគ៖ ដំណើរការរៀបចំថវិកាអាចឱ្យបុគ្គលនិង អង្គការ នានាកំណត់ឱកាសសម្រាប់ការសន្សំការចំណាយ ការកែលម្អប្រសិទ្ធភាព និងការវិនិយោគជា យុទ្ធសាស្ត្រ។ បើគ្មានការរៀបចំគម្រោងថវិកាច្បាល់លាស់ទេ វាអាចនឹងខកខានឱកាសក្នុងការសន្សំប្រាក់វិនិយោគលើគំនិតផ្តួចផ្តើមកំណើនឬ កសាងសន្តិសុខហិរញ្ញវត្ថុ។

• កាត់បន្ថយភាពធន់នឹងហិរញ្ញវត្ថុ៖ ដំណើរការរៀបចំថវិកាជួយបង្កើតភាពធន់ផ្នែកហិរញ្ញវត្ថុដោយការ ធ្វើផែនការសម្រាប់ភាពអាសន្ន ការចំណាយដែលមិនរំពឹងទុក ឬការធ្លាក់ចុះសេដ្ឋកិច្ច បើគ្មានដំណើរការរៀបចំថវិកាទេបុគ្គល និងអង្គការនានាងាយរងគ្រោះទៅនឹងវិបត្តិហិរញ្ញវត្ថុ ការរំខាន ឬវិបត្តិដែលអាចប៉ះពាល់ ដល់ស្ថិរភាព និងនិរន្តរភាពហិរញ្ញវត្ថុរបស់ពួកគេ។

សរុបមក ការមិនមានដំណើរការរៀបចំថវិកាអាចបណ្តាលឱ្យមានហិរញ្ញវត្ថុមិនប្រក្រតី ការសម្រេចចិត្ត មិនល្អខកខានឱកាស និងអស្ថិរភាពហិរញ្ញវត្ថុ។ ការអនុវត្តដំណើរការរៀបចំថវិកាដែលមានរចនាសម្ព័ន្ធ វាមានសារៈសំខាន់សម្រាប់ការសម្រេចបាននូវគោលដៅហិរញ្ញវត្ថុការគ្រប់គ្រងធនធានប្រកបដោយ ប្រសិទ្ធភាព និង ធានានូវភាពជោគជ័យផ្នែកហិរញ្ញវត្ថុរយៈពេលវែង។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ឆ្លងតាមការសិក្សាស្រាវជ្រាវទៅលើក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ខូអិលធីឌី ក្រុមយើងខ្ញុំបានសង្កេតឃើញថានៅក្នុងដំណើរការនៃការគ្រប់គ្រងប្រតិបត្តិការរបស់ក្រុមហ៊ុនមួយតែងតែបង្កប់នៅចំណុចខ្លាំង និងចំណុចខ្សោយ ហើយការវិភាគលើចំណុចទាំងនេះវាពិតជាមានសារៈសំខាន់ណាស់ ព្រោះវាបានផ្តល់ភាពងាយស្រួលក្នុងការវាយតម្លៃពីសកម្មភាពរបស់ក្រុមហ៊ុនដើម្បីមានភាពអភិវឌ្ឍ និងរីកចម្រើនទៅមុខ។ ដោយផ្អែកទៅលើទិន្និន័យព័ត៌មានដែលទទួលបានកន្លងមក។

ក្រុមយើងខ្ញុំបានរកឃើញនៅចំណុចខ្លាំង និងចំណុចខ្សោយ របស់ក្រុមហ៊ុនដែរត្រូវបំពេញបន្ថែមដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

ក្រុមហ៊ុនមានការរៀបចំគម្រោងថវិកាបានយ៉ាងល្អដោយប្រើវិធីសាស្រ្តក្នុងការរក្សា និងក្រុមសាច់ប្រាក់យ៉ាងមានប្រសិទ្ធភាព ការចំណាយមានលក្ខណៈច្បាស់លាស់តាមក្បួនខ្នាតច្បាប់គណនេយ្យ និងមានបែងចែកថវិកា តាមផ្នែកនីមួយៗតាមស្ថានភាពជាក់ស្តែងដូចជា៖

- **ការគ្រប់គ្រងចំណាយយ៉ាងម៉ត់ចត់៖** ក្រុមហ៊ុនមានការយកចិត្តទុកដាក់ខ្ពស់ និងប្រុងប្រយ័ត្នក្នុងការចំណាយធ្វើឱ្យការចំណាយមានសីលធម៌ និងត្រឹមត្រូវតាមគោលនយោបាយ។
- **ការត្រួតពិនិត្យប្រចាំខែ និងការចំណាយដើមខែ៖** ការចំណាយដ៏សំខាន់ៗភាគច្រើនកើតមាននៅដើមខែដែលជាថ្ងៃដំបូងនៃការដំណើរការប្រតិបត្តិការបានយ៉ាងរលូន ហើយក្រុមហ៊ុនក៏ធ្វើការវិភាគប្រភេទចំណាយណាដែលគួរកាត់បន្ថយ និងណាដែលមិនគួរកាត់បន្ថយ។
- **ប្រព័ន្ធសក្ខីបត្របានរៀបចំយ៉ាងម៉ត់ចត់៖** រាល់ចំណាយត្រូវមានសក្ខីបត្រច្បាស់លាស់ ហើយភ្ជាប់ជាមួយវិក្កយបត្រដែលបញ្ជាក់ពីឈ្មោះទំនិញ ចំនួនប្រាក់សរុប និងឈ្មោះអ្នកផ្គត់ផ្គង់ អាសយដ្ឋាន និងថ្ងៃខែឆ្នាំត្រឹមត្រូវព្រមទាំងមានហត្ថលេខារបស់អ្នកទទួលខុសត្រូវ។
- **ការស្នើសុំថវិកាតាមលិខិតជាផ្លូវការជានិច្ច៖** រាល់ការចំណាយត្រូវមានលិខិតស្នើសុំជាអក្សរដែលមានការយល់ព្រមពីប្រធានក្រុមហ៊ុន និងប្រធានផ្នែកហិរញ្ញវត្ថុ ដើម្បីធានាថាជាការចំណាយត្រឹមត្រូវ និងសមហេតុផល។
- **សក្ខីបត្រដើមបានរៀបចំយ៉ាងល្អ៖** មានទម្រង់សំណើរច្បាស់លាស់ដូចជា សម្រង់ថ្លៃសំណើរស្នើសុំ និងឯកសារដទៃទៀតដែលទាក់ទងជាប្រព័ន្ធ។
- **ការកែលម្អប្រព័ន្ធគ្រប់គ្រង៖** ក្រុមហ៊ុនបានយកចិត្តទុកដាក់លើការកែលម្អទម្រង់ប្រព័ន្ធគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ជាជំហានមួយ នៃការបង្កើតជោគជ័យអាជីវកម្ម។
- **ការរៀបចំគម្រោងចំណាយប្រចាំឆ្នាំមានភាពច្បាស់លាស់៖** ការរៀបចំថវិកាបានអនុវត្តតាមដំណាក់កាលជាក់លាក់ដោយអាចវាស់វែងអត្រាចំណាយ និងត្រួតពិនិត្យបានយ៉ាងមានប្រសិទ្ធភាព។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងចំណុចខ្លាំងដែលក្រុមហ៊ុនមាន យើងក៏ឃើញមានចំណុចខ្សោយមួយចំនួនដែលត្រូវបានសង្កេតឃើញដូចតទៅ៖

**១. ការបាត់បង់ការគ្រប់គ្រងហិរញ្ញវត្ថុ៖**

- មិនមានការគ្រប់គ្រងល្អ អាចនាំឱ្យមានការចំណាយលើស និងការចំណាយលើអ្វីដែលមិនមានប្រយោជន៍ច្រើន។
- ការប្រើប្រាស់ប្រាក់ដោយគ្មានគោលបំណងច្បាស់លាស់អាចបង្កបញ្ហាទាក់ទងនឹងមុខងារបង់ប្រាក់ និងការសម្រេចចិត្តថវិកាដែលនាំឱ្យប្រតិបត្តិការហិរញ្ញវត្ថុខូចខាត។

**២. បញ្ហាក្នុងការប្រមូលប្រាក់សម្រាប់គោលបំណងធំៗ៖**

- ការខ្វះប្រព័ន្ធក្នុងការរកប្រាក់សម្រាប់គោលបំណងធំៗ ធ្វើឱ្យក្រុមហ៊ុនមិនអាចរក្សាទុកទុន ឬសន្សំពេលវេលាសម្រាប់ការវិនិយោគអនាគតបានយ៉ាងមានប្រសិទ្ធភាព។
- អ្នកប្រើប្រាស់ប្រាក់អាចនឹងចំណាយលើសកម្មភាពដែលមិនសំខាន់ ឬមិនចាំបាច់ដោយគ្មានការត្រួតពិនិត្យយ៉ាងតឹងរឹង។

**៣. បញ្ហាការអភិវឌ្ឍសេដ្ឋកិច្ច៖**

- ការបាត់បង់ការគ្រប់គ្រងអាចបញ្ចេញលទ្ធផលលើសកម្មភាពអភិវឌ្ឍ និងការកើនមានឡើងនូវបំណុលជាច្រើន។
- នេះធ្វើឱ្យមិនមានការរួមចំណែកយ៉ាងមានប្រសិទ្ធភាពចំពោះការរកចំណូល និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមការស្រាវជ្រាវ និងការវិភាគលើប្រធានបទ «**ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន PTC Computer Co., LTD**» ក្រុមយើងបានសន្និដ្ឋានថា ការរៀបចំគម្រោងថវិកាជាដំណើរការដ៏មានសារៈសំខាន់និងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនចំពោះស្ថាប័ន។ ការរៀបចំថវិកានេះវាជួយឱ្យមានភាពងាយស្រួលក្នុងការរៀបចំចំណូលចំណាយ កាត់បន្ថយការចំណាយដោយអត់បានការចាំបាច់ និងកំណត់ប្រភពចំណូលបានយ៉ាងច្បាស់លាស់។ លើសពីនេះក៏បានជួយឱ្យក្រុមហ៊ុនមានភាពរីកចម្រើន និងពង្រីកសាខាបានជាច្រើននៅក្នុងប្រទេសកម្ពុជា ជាពិសេសគឺរាជធានីភ្នំពេញ។

ម្យ៉ាងវិញទៀត ការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន **ភីធីស៊ី កុំព្យូទ័រ**មានដំណើរនិងការរៀបចំបានយ៉ាងល្អ និងមានប្រសិទ្ធភាពពិតៗ ព្រោះការរៀបចំគម្រោងថវិកា នៅក្នុងក្រុមហ៊ុន **ភីធីស៊ី កុំព្យូទ័រ** មានការរៀបចំរបាយការណ៍ការត្រួតពិនិត្យ មាននីតិវិធីក៏ដូចជាវិធីសាស្ត្រក្នុងការគ្រប់គ្រងចំណូលចំណាយបានយ៉ាងមានប្រសិទ្ធភាព។ បន្ថែមពីលើនេះទៅទៀត ក្រុមហ៊ុន **ភីធីស៊ី** ក៏បានធ្វើការកត់ត្រា និងត្រួតពិនិត្យរបាយការណ៍ប្រចាំថ្ងៃដោយការកត់ត្រា និងសរសេរលើនៅលើសៀវភៅបញ្ជីគណនេយ្យរួមទាំងអនុវត្តន៍ទៅតាមផែនការដែលបានគ្រោងទុកដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ និងច្បាស់លាស់។

ហើយលើសពីនេះ តាមរយៈការសិក្សាក៏ដូចជាតាមការវិភាគនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុក៏បានបង្ហាញឱ្យដឹងអំពីការគ្រប់គ្រងនៃការប្រើប្រាស់ធនធានក្នុងគម្រោងថវិការនៅក្នុងក្រុមហ៊ុន PTC Computer Co., LTD គឺជាក្រុមហ៊ុនដែលមានស្ថេរភាពនៅក្នុងប្រតិបត្តិការមានគោលនយោបាយច្បាស់លាស់ក្នុងការបែងចែកធនធាន និងគ្រប់គ្រងចំណូលចំណាយក្នុងការលក់ផលិតផលរបស់ខ្លួន។ ការអនុវត្តន៍នៃគម្រោងថវិកាគឺជាចំណុចមួយដែលជួយអោយស្ថាប័នមានស្ថេរភាព និងប្រសិទ្ធភាពក្នុងប្រតិបត្តិការ។ ផ្ទុយទៅវិញក្រុមហ៊ុនក៏បានធ្វើការចំណាយយ៉ាងច្រើនទៅលើផលិតផលបរាជ័យមួយចំនួនរបស់ខ្លួនដែលធ្វើឱ្យមានការប៉ះពាល់ទៅលើចំណូលមួយផ្នែកធំរបស់ក្រុមហ៊ុន។

សរុបមក យោងតាមការស្រាវជ្រាវនិងពិភាក្សាគ្នាយ៉ាងសកម្មទៅលើសារណារបស់ក្រុមយើងខ្ញុំទៅលើប្រធានបទ« ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ » រួចមកក្រុមយើងខ្ញុំអាចសន្និដ្ឋានបានថា ដំណើរការរៀបចំគម្រោងថវិកា គឺពិតជាមានសារៈសំខាន់ដែលអាចឱ្យក្រុមហ៊ុនមានភាពរីកចម្រើនគ្មានការខាតបង់នាពេលអនាគត។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានឆ្លងកាត់នូវការធ្វើសេចក្តីសន្និដ្ឋានខាងលើ « **ដំណើរការនៃការរៀបចំគម្រោងថវិកាក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ** » រួចមកក្រុមយើងខ្ញុំយល់ឃើញថា ក្រុមហ៊ុនពិតជាបានធ្វើទៅតាមគម្រោងដែរបានរៀបចំបានល្អិតល្អន់ និងមានភាពច្បាស់លាស់ពិតប្រាកដមែន។ ប៉ុន្តែនៅពីក្រោយភាពជោគជ័យរបស់ក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ យើងក៏បានសង្កេតឃើញថាក្រុមហ៊ុននៅមាននូវចំណុចខ្វះខាតមួយចំនួនដែលត្រូវកែលម្អរផងដែរ។ ហេតុដូចនេះហើយក្រុមយើងខ្ញុំសុំធ្វើការបញ្ចេញមតិយោលបល់និងផ្តល់អនុសាសន៍មួយចំនួនអំពីក្រុមហ៊ុន ភីធីស៊ី កុំព្យូទ័រ ដែលស្ថិតនៅក្នុងន័យស្ថាបនា ដើម្បីជួយជម្រុញឱ្យក្រុមហ៊ុនកាន់តែមានភាពងាយស្រួល និងកាន់តែច្បាស់លាស់បន្ថែមចំនួនទៀតដែលមានដូចខាងក្រោម ៖

១. ក្រុមហ៊ុនគួរតែបន្តការកាត់បន្ថយ និងបង្កើនវិធីសាស្រ្តក្នុងការចំណាយ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់ និងអាចទទួលបានចំណេញក្នុងពេលវេលាដ៏មានប្រយោជន៍។

២. ក្រុមហ៊ុនត្រូវដាក់បញ្ជាក់និងត្រួតពិនិត្យគុណភាពផលិតផលយ៉ាងម៉ត់ចត់ មុនដាក់ចេញលក់ដល់អតិថិជន ដើម្បីធានាបានថាផលិតផលមានគុណភាពល្អ និងបំពេញតាមតម្រូវការ។

៣. ក្រុមហ៊ុនគួរតែយកចិត្តទុកដាក់លើការគ្រប់គ្រងចំណូល និងការចំណាយតាមផ្នែកនីមួយៗដើម្បីជៀសវាងការខ្វះខាត ការធ្វេសប្រហែល និងបាត់បង់ធនធាន។

៤. ក្រុមហ៊ុនត្រូវការវិនិយោគក្នុងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ និងការគ្រប់គ្រងទំនាក់ទំនងអតិថិជនដើម្បីបន្តការប្រកួតប្រជែង និងបង្កើនសមត្ថភាពនៅលើទីផ្សារ។

ជាចុងក្រោយ នៃការស្រាវជ្រាវនេះក្រុមយើងខ្ញុំជឿជាក់ថាការផ្តល់មតិយោបល់និងអនុសាសន៍មួយចំនួនរបស់ក្រុមយើងខ្ញុំ គ្រាន់តែជាការរួមចំណែកមួយក្នុងការបំពេញចំណុចខ្វះខាត និងការស្ថាបនាក្រុមហ៊ុនឱ្យកាន់តែមានភាពរីកចម្រើនឡើង ដែលអាចផ្តល់សេវាកម្មឱ្យអតិថិជនដោយមានភាពពេញចិត្ត និងមានលទ្ធភាព រឹងមាំក្នុងការប្រកួតប្រជែងគ្នានៅលើទីផ្សារសេរី។

# ឯកសារយោង

# ឯកសារយោង


➢ ឯកសារយោងក្នុងបណ្ណាល័យដែលបានបន្សល់ទុក

2. រៀបរៀងដោយនិស្សិតឈ្មោះ ស៊ឹម ស្រីពេជ, អឿង ណារ៉ា, គុយ នាគ, អែម ស្រីឃីម. (២០២១). ប្រធានបទ៖ *ដំណើរការនៃការរៀបចំគម្រោងថវិការបស់ក្រុមហ៊ុន កូកា-កូឡា.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២១ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៥។ ភ្នំពេញ។
3. រៀបរៀងដោយនិស្សិតឈ្មោះ ជីវ ម៉ីម៉ី, ស៊ឹម ស្រីពេជ, សុខ ផាណាត់, ថ្លាង សុខហេង, យាង លីឆេង. (២០២១). ប្រធានបទ៖ *អត្ថប្រយោជន៍នៃការរៀបចំគម្រោងចំណាយរបស់ ក្រុមហ៊ុនខ្មែរប៊ែវើជីស.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី១៩ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៤. ភ្នំពេញ។
4. រៀបរៀងដោយនិស្សិតឈ្មោះ ស្មាន ដារ៉ា, មុំ រតនា, ប្រៃ ស្រីឡី, គង់ វនីន. (២០២៣). ប្រធានបទ៖ *អត្ថប្រយោជន៍រៀបចំគម្រោងថវិការបស់ក្រុមហ៊ុន មេនូឡាយហ្វ៍.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៦. ភ្នំពេញ។
5. រៀបរៀងដោយនិស្សិតឈ្មោះ សេន ធីម, ឡេង សុភា, ហាន មិនា, ភិ សុផា, ឃី គីមឆៃ. (២០២៣). ប្រធានបទ៖ *ការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន ភី ធី ស៊ី កុំព្យូទ័រ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២០ នៃវិទ្យាស្ថាន វ៉ាន់ ដា. ទំព័រទី៧. ភ្នំពេញ។

➢ ឯកសារយោងតាមការស្រាវជ្រាវ : Internet, Google, Social Media

- OECD. *Public finance and budgets*. Retrieved June 4 2025 from https://www.oecd.org/gov/budgeting
- Ministry of Economic and Finance. *State Budget Implementation*. Retrieved June 4 2025 from https://mef.gov.kh/download-counter?post=11003
- The NGO Form on Cambodia. *ការពិនិត្យមើលក្របខ័ណ្ឌច្បាប់ និងគោលនយោបាយស្តីពីការចូលរួមរបស់សាធារណៈជនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា.* Retrieved June 4 2025 from https://www.cambodianbudget.org/files-tinymce/New_Pic/A_LEGAL_AND_POLICY_FRAMEWORK_REVIEW_ON_PUBLIC_PARTICIPATION_IN_PUBLIC_FINANCIAL_MANAGEMENT_IN_CAMBODIA_Kh.pdf.
- សារាចរណែនាំស្តីពីការរៀបចំការយុទ្ធសាស្រ្តថវិកា(ឆ្នាំ២០២៣-២០២៤). Retrieved June 4 2025 from https://ad.mef.gov.kh/file-upload/ad-mef-gov-kh-n6-001-165785856889691.pdf.
- Accounting and Auditing Regulator. (2025, January 11). Retrieved June 4 2025 from https://www.acar.gov.kh/standard/page/28

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ


ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
VANDA INSTITUTE
TOPIC: COCA COLA BUDGET MANAGEMENT PROCESS
B21/1074
B21/1390
B21/1712
B21/774
VIA.PP/2024


MINISTRY OF EDUCATION YOUTH AND SPORTS
VANDA INSTITUTE
TOPIC: THE BENEFITS OF KHMER BEVERAGES
COST PLANNING
B19/627
B19/3055
B19/532
B19/706
B19/3072
VIA .013.220
Library/2022
PHNOM PEN


ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថាន វ៉ាន់ដា
TOPIC: EXPENSES MANAGEMENT OF PTC COMPUTER COMPANY
B20/676
B20/821
B20/1126
B20/1127
B20/2017
016.303
VIA.PP/2023
និស្សិតជំនាន់ទី២០
PHNOM PENH-2023


ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថាន វ៉ាន់ដា
TOPIC: BENEFIT OF BRAPARING THE COMPANY'S EXPENSE PROJECT
MANULIFE CAMBODIA
B20/1814
B20/1013
B20/082
B20/103
016.269
VIA.PP/2023
និស្សិតជំនាន់ទី២០
PHNOM PENH-2023



